សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងកាកសំណល់រឹង នៅរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ លោក **ស៊ុម ច័ន្ទតារា** | បណ្ឌិត **ឈុន ណារ៉េត** |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | | ឆ្នាំចូលរៀន | ២០១៣ |
| ជំនាន់ទី ១០ ( អាហារូបករណ៍ ) | | ឆ្នាំសរសេរសារណា | ២០១៧ |

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ស៊ុម ច័ន្ទតារា** សូមគោរពប្រណិបត្តិ និងថ្លែងអំណរគុណដ៍ជ្រាលជ្រៅជាទីបំផុតរកអ្វីកាត់ថ្លៃពុំបាន ចំពោះ**លោក ឪពុក អ្នកម្តាយ** អ៊ុំ ឭ មឹង ដែលលោកទាំងអស់មានគុណដ៍សែនធ្ងន់ចំពោះកូន បានផ្តល់កំណើតដល់កូន ថ្នាក់ថ្នម ចិញ្ចឹមបីបាច់ ថែរក្សា ការពារ អប់រំ ទូន្មានប្រៀនប្រដៅកូន លះបង់ទាំងកម្លាំងកាយចិត្ត និង ពេលវេលាដ៍មានតំលៃ ដើម្បីអោយកូនរស់នៅយ៉ាងសុខដុមរមនាជាពិសេសជាងនេះទៅទៀត អ្នកបានផ្តល់លទ្ធភាពដល់កូន អោយកូនបានសិក្សា តាំងពីបឋមសិក្សា រហូតចប់ឧត្តមសិក្សាព្រមទាំងចំណាយកំលាំងញើសឈាម មិនថា យប់ មិនថាថ្ងៃ ក្តៅរងា ភ្លៀង ខ្យល់ឡើយ មិនតែប៉ុណ្ណោះ លោកអ្នកមានគុណកំពុងត្រួសត្រាយផ្លូវអោយកូន ដើម្បីអោយកូនក្លាយជាមនុស្សម្នាក់ដែលមានប្រយោជន៍សំរាប់សង្គមជាតិ។

សូមលោកអ្នកមានគុណទាំងអស់ ទទួលបានសេចក្តីសុខសប្បាយ និងសុភមង្គលកុំបីឃ្លៀងឃ្លាតឡើយ និងសូមបួងសួងដល់ព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកថែរក្សាលោកអ្នកមានគុណអោយបានសេចក្តីសុខចំរើន អាយុយឺនយូរ ជាម្លប់ផ្តល់ភាពកក់ក្តៅដល់កូន។

**ឯកឧត្តមអភិបាលរាជធានីភ្នំពេញ នាយក-នាយករង ទីចាត់ការគ្រប់គ្រងកាកសំណល់ ស្ថាប័នឯកជនស៊ីនទ្រី (CINTRI)** និង គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានបង្កលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ និងការប្រមូលឯកសារក្នុងការសរសេរសារណារបស់ខ្ញុំបាទ។

**ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស** ព្រមទាំងលោក លោកស្រីដែលជាសាស្ត្រាចារ្យ បុគ្គលិកទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានជួយជ្រោមជ្រែងគ្រប់បែបយ៉ាងក្នុងការជួយខ្ញុំបាទអោយមានលទ្ធភាពងាយស្រួលក្នុងការសិក្សានេះ។

លោកសាស្ត្រាចារ្យ **បណ្ឌិត ឈុន ណារ៉េត** ដែលបានណែនាំ និង ផ្តល់គំនិតល្អៗដល់ខ្ញុំបាទ ក្នុងរយះពេលធ្វើសារណា ។

សូមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តមអភិបាលក្រុង អភិបាលខណ្ឌ ស្ថាប័នឯកជន ស៊ីនទ្រី (CINTRI) ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស ព្រមទាំងលោក លោកស្រីដែលជាសាស្ត្រាចារ្យទទួលបានប្រសិទ្ធិពរជ័យ សិរីមង្គល និងទទួលនូវពុទ្ធពរទាំង៥ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

សារណានេះតាក់តែងឡើង ដើម្បីជំនួយដល់ការសិក្សាសម្រាប់ថ្នាក់បរិញ្ញាប័ត្រខាងរដ្ឋបាលសាធារណៈនេះ គឺជាលទ្ធផលដែលបានកើតចេញមកពីការខិតខំប្រឹងប្រែងនិង ស្រាវជ្រាវរបស់ខ្ញុំបាទ រួមផ្សំនិងការសិក្សាអស់រយៈពេលបួនឆ្នាំ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ ខ្ញុំបាទ បានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី “ **ការគ្រប់គ្រងកាកសំនល់រឹងនៅរាជធានីភ្នំពេញ** ” ដើម្បីបន្សល់ទុកជាឯកសារ ស្រាវជ្រាវសម្រាប់ជូន សិស្ស និស្សិត និងបណ្តាអ្នកសិក្សាស្រាវជ្រាវ ទាំងឡាយ ដែលមានបំណងធ្វើការស្រាវជ្រាវ លើប្រធានបទដែលមានពាក់ព័ន្ធនឹងប្រធានបទដែលខ្ញុំបាទ ធ្វើការស្រាវជ្រាវ និង ធ្វើការចងក្រងជាសារណានេះទុក។ ការសរសេរជាសារណាដើម្បីបញ្ចប់ការសិក្សារបស់ខ្ញុំបាទនេះ ខ្ញុំបាទបានទទួលនូវការសហការ ផ្តល់ឯកសារនានា ការណែនាំការផ្តល់គំនិតយោបល់ល្អៗ ជាពិសេសការជ្រោមជ្រែងនិងការផ្តល់មតិយោបល់ល្អៗ ពីលោកអភិបាលក្រុងរាជធានីភ្នំពេញតែម្តង។

សារណានេះ គឺចង់បង្ហាញពីការគ្រប់គ្រងនៅកាកសំនល់រឹងនៅរាជធានីភ្នំពេញ ដោយក្នុងគោលបំណងចង់បង្ហាញជាចំនេះដឹង និង យុទ្ធសាស្ត្រនៃគ្រប់គ្រងកាកសំនល់នៅរាជធានីភ្នំពេញ ដើម្បីផ្សព្វផ្សាយអោយបានទូលំទូលាយដល់ប្រជាពលរដ្ឋខ្មែរ និងចាំបាច់ត្រូវមានការចូលរួមពីប្រជាពលរដ្ឋម្នាក់ៗក្នុងការធ្វើអោយទីក្រុងមានសោភ័ណភាព និងអាចជាគំរូដល់កូនចៅជំនាន់ក្រោយ។

ខ្ញុំបាទសូមអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងដោយអចេតនាទាំងឡាយណា ដែលមានកើតឡើងក្នុងការសរសេរ សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ រដ្ឋបាលសាធារណៈ របស់ខ្ញុំបាទ ហើយខ្ញុំបាទនឹងត្រៀមខ្លួនជានិច្ច ដោយរង់ចាំទទួលនូវមតិរិះគន់កែលម្អរក្នុងន័យស្ថាបនា យ៉ាងខ្ពង់ខ្ពស់ពីសំណាក់សិស្សនិស្សិតអ្នកស្រាវជ្រាវ និងមិត្តអ្នកអានទាំងអស់ ហើយសង្ឃឹមថា មិត្តអ្នកអានទាំងអស់នឹងជួយផ្តល់ជាមតិ និងគំនិតល្អៗបន្ថែមទៀត ក្នុងការកែលម្អរសារណានេះអោយកាន់តែ ប្រសើរឡើងថែមទៀត ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម**........................................................................................................ ០១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ....................................................................................... ០១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ..................................................................................... ០២
៣. គោលបំណងនៃការស្រាវជ្រាវ ....................................................................................... ០២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ............................................................................. ០២
៥. សារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ......................................................................... ០២
៦.វិធីសាស្ត្រនៃការស្រាវជ្រាវ.............................................................................................០៣
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .........................................................................................០៣
**ជំពូកទី១ ៖ រដ្ឋបាលដែនដីថ្នាក់រាជធានី** ........................................................................ ០៤
**១-១.ទីតាំងភូមិសាស្ត្រ**................................................................................................... ០៤
១.១.១. ស្ថានភាពទូទៅ ........................................................................................ ០៤
១.១.២. រដ្ឋបាលដែនដី.......................................................................................... ០៤
១.១.២.១. ទីតាំងភូមិសាស្ត្ររាជធានីភ្នំពេញ .................................................... ០៤
១.១.២.២. ការបែងចែកមណ្ឌលរដ្ឋបាលដែនដី ................................................. ០៥
១.១.២.៣. ស្ថានភាពប្រជាជន ........................................................................ ០៥
១.១.២.៤. ច្រកទ្វារនៃកំណើនសេដ្ឋកិច្ច.............................................................. ០៥
**១-២ ការគ្រប់គ្រងកាកសំណល់ថ្នាក់រាជធានី**..................................................................... ០៦
១.២.១. រចនាសម្ព័ន្ធសាលាក្រុង និងសមាសភាពថ្នាក់ដឹកនាំ.......................................... ០៦
១.២.២. តួនាទី និង ភារកិច្ច ........................................................................................ ០៦
១.២.៣. ទីចាត់ការគ្រប់គ្រងកាកសំណល់ .................................................. ០៧
១.២.៣.១. តួនាទី និងភារកិច្ចរបស់ទីចាត់គ្រប់គ្រងកាកសំណល់..................... ០៧
១.២.៣.២. ផែនការយុទ្ធសាស្ត្រ និងសកម្មភាពនៃការគ្រប់គ្រងសំណល់............ ០៧
១.២.៤. ការិយាល័យចំនុះទីចាត់ការគ្រប់គ្រងកាកសំណល់ ...................... ១៣
១.២.៥. ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន......... ១៣
១.២.៥.១. តួនាទី និង ភារកិច្ច ........................................................................ ១៣
១.២.៦. ការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់.................................. ១៤

១.២.៦.១. តួនាទី និង ភារកិច្ច............................................................................ ១៤
**ជំពូកទី២ ៖ ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញសម្រាម និង វិធានការនៃការគ្រប់គ្រងសម្រាម**..................................................................................... ១៥
**២-១.ការញែក ការវេចខ្ចប់ និង ការទុកដាក់** ................................................................. ១៥
២.១.១. សមាសភាពអ្នកអនុវត្តរបស់ម្ចាស់សំរាម ......................................................... ១៥
២.១.២. ការទទួលខុសត្រូវរបស់អ្នករក្សាការវេចខ្ចប់ ការទុកដាក់........................... ១៥
២.១.២.១. ការបង់ថ្លៃ របស់ម្ចាស់សំរាម.................................................................. ១៦
**២-២.វិធានការនៃការគ្រប់គ្រងសម្រាម និង ការបង់ប្រាក់ពិន័យលើទោស**.................... ១៦
២.២.១. វិធានការទូទៅ .................................................................................................. ១៦
២.២.២. វិធានការគ្រប់គ្រង ទីលានទុកដាក់សំរាម......................................................១៧
២.២.៣. ការពិន័យ ..........................................................................................................១៧
**ជំពូកទី៣ ៖ វិស័យឯកជនលើការគ្រប់គ្រងកាកសំណល់** ......................................... ២១
**៣-១.ការគ្រប់គ្រងកាកសំណល់របស់ក្រុមហ៊ុន ស៊ីន ទ្រី (ខេមបូឌា)**...........................២១
៣.១.១. អំពីក្រុមហ៊ុន.................................................................................................... ២១
៣.១.២. រចនាសម្ព័ន្ធ ក្រុមហ៊ុន ស៊ីន ទ្រី.............................................................................២១
**៣-២.ចក្ខុវិស័យ និង សកម្មភាពនៃការគ្រប់គ្រងកាកសំណល់** .................................. ២១
៣.២.១. ចក្ខុវិស័យ............................................................................................................ ២១
៣.២.២. សមិទ្ធផល និងការសម្រេចបានក្នុងការគ្រប់គ្រងកាកសំណល់ .....................២២
៣.២.២.១ ការអភិវឌ្ឍរបស់ក្រុមហ៊ុន.........................................................................២២
៣.២.២.២ ទំងន់សំរាមដែលក្រុមហ៊ុនដឹកប្រចាំខែ ............................................... ២៣
៣.២.២.៣ តំបន់សេវា និងការពង្រីកបន្ថែមរបស់ក្រុមហ៊ុន ................................. ២៣
៣.២.២.៤ សកម្មភាព និងលទ្ធផលការងារ..........................................................២៤

**ជំពូកទី៤ ៖ បញ្ហាប្រឈម និង ដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់**........ ២៦
**៤-១.បញ្ហាប្រឈម** ........ ២៦
៤.១.១ បញ្ហាប្រឈមក្នុងការគ្រប់គ្រងកាកសំណល់នៃសាលារាជធានីភ្នំពេញ........ ២៦
៤.១.២ បញ្ហាប្រឈមក្នុងការគ្រប់គ្រងកាកសំណល់នៃក្រុមហ៊ុន ស៊ីន ទ្រី ........ ២៦
៤.១.៣ បញ្ហាប្រឈមក្នុងការគ្រប់គ្រងកាកសំណល់របស់ប្រជាពលរដ្ឋ ........ ២៨
**៤-២.ដំណោះស្រាយ** ........ ២៩
៤.២.១ ដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់នៃសាលារាជធានីភ្នំពេញ ........ ២៩
៤.២.២ ដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់របស់ក្រុមហ៊ុន ស៊ីនទ្រី........ ២៩
៤.២.៣ ដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់របស់ប្រជាពលរដ្ឋ ........ ៣០
**សេចក្តីសន្និដ្ឋាន**........ ៣២
**អនុសាសន៍**........ ៣៤
**ឯកសារយោង**........ ៣៥
**ឧបសម្ព័ន្ធ**........ ៣៦

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានឆ្លងកាត់ការផ្លាស់ប្តូររបបនយោបាយ ក៏ដូចជាសង្គ្រាមទាំងផ្ទៃក្នុង ជាមួយនិងប្រទេសជិតខាងជាច្រើនលើកច្រើនសារ។ លើសពីនេះទៅទៀតក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាដែលស្ថិតនៅក្រោមការដឹកនាំរបស់ ប៉ុល ពត បានធ្វើអោយប្រទេសជាតិទទួលរងនូវវិនាសកម្មយ៉ាងធំធេងបំផុត ពោលគឺ របបនោះត្រូវបានគេហៅថារបបប្រល័យពូជសាសន៍ ។ ក្រោយការផ្តួលរលំ ប្រទេសកម្ពុជាយើងបានខិតខំប្រឹងប្រែង និង ឥតឈប់ឈររបស់ថ្នាក់ដឹកនាំកម្ពុជា និងបានរៀបចំប្រទេសដោយបាតដៃទទេ ក្លាយជាប្រទេសដែលមានអធិបតេយ្យ និងមានការទទួលស្គាល់ពីមជ្ឈដ្ឋានពិភពលោក។

ដើម្បីទទួលបានប្រទេសអោយមានភាពកាន់តែ រីកចម្រើន ក៏ដូចជាការផ្តោតសំខាន់ទៅលើ សោភ័ណភាពទីក្រុង អោយមានភាពទាក់ទាញ ចាំបាច់ត្រូវមានការគ្រប់គ្រងទៅលើបរិស្ថាន ជាពិសេសគឺកាកសំណល់រឹង ដែលកើតចេញពីរបស់របរប្រើប្រាស់ប្រជាពលរដ្ឋប្រចាំថ្ងៃ ដូចជាថង់ អាហារ សម្លៀកបំពាក់ចាស់ៗ ដប កំប៉ុង ស្បែកជើងចាស់ៗ បន្លែ ជ័រ និងអ្វីផ្សេងៗទៀត ដែលគេលែងប្រើប្រាស់ នោះគេចាត់ទុកថាជាកាកសំណល់ដែលអត់ប្រយោជន៍ និងត្រូវបោះវាចោល។

សំណល់រឹងគឺជារូបធាតុនានា ដែលគ្មានសារៈប្រយោជន៍ទៀត នៅក្នុងទំរង់ ឬលក្ខខណ្ឌបច្ចុប្បន្នរបស់វា ។ ការគ្រប់គ្រងកាកសំណល់គឺជាការទុកដាក់រូបធាតុសំណល់ ដែលកើតមកពីប្រភពឧស្សាហកម្ម គេហដ្ឋាន ឬឧស្សាហកម្ម តាមរបៀបមួយដែលចំណាយតិច និងគ្មានការខូចខាតបរិស្ថាន ។ កំណើនចំនួនប្រជាជន កំណើនកំរិតជីវភាពរស់នៅ កំណើននគរូបនីយកម្ម និងឧស្សាហកម្ម បាននាំមកនូវបរិមាណសំណល់រឹងកាន់តែច្រើន នៅប្រទេសឧស្សាហកម្ម ដូចជា សហរដ្ឋអាមេរិច ជប៉ុន សឹង្ហបុរី ឬ បារាំង ក៏ដូចជានៅប្រទេសកំពុងលូតលាស់ ដូចជាកម្ពុជា និងឥណ្ឌាជាដើម ។

សំណល់រឹងមានឥទ្ធិពលធ្ងន់ធ្ងរទៅលើសុខភាពសាធារណៈ និង បរិស្ថាន ប្រសិនបើគេស្តុកប្រមូល និងចាក់ចោលដោយមិនត្រឹមត្រូវ។ ផលប៉ះពាល់ខ្លាំងជាងគេ ដែលបណ្តាលមកពីការគ្រប់គ្រងសំណល់រឹងមិនបានល្អរួមមាន ៖ ការបំពុលខ្យល់ ការបំពុលទឹកផឹក និងការចំលងជំងឺរាតត្បាតដល់មនុស្ស ។ វាបានធ្វើអោយទីក្រុងបាត់បង់សោភណ្ឌភាព និងកខ្វក់ ប៉ះពាល់ដល់សុខភាព និងផ្លូវចិត្តរបស់មនុស្ស ហើយអាចធ្វើអោយមានគ្រោះថ្នាក់ដល់សត្វ និងរុក្ខជាតិនិងប្រឈមក្នុងការទទួលឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ច និងមោទនភាពជាតិ ។

ការគ្រប់គ្រងកាកសំណល់គឺជាចំណោទដ៏ចំបង ដែលរដ្ឋាភិបាលនានាលើពិភពលោកប្រឈមមុខ ពិសេសនៅកម្ពុជា សំណល់រឹងគឺជាការបំពុលដែលឃើញជាក់ស្តែងបំផុត។ ការគ្រប់គ្រងកាកសំណល់ ការប្រមូល និងដឹកជញ្ជូនសំណល់រឹងនៅភ្នំពេញ គឺជាបញ្ហាដ៏គួរអោយព្រួយបារម្ភរបស់សាលាក្រុង ដែល

ជាអ្នកទទួលខុសត្រូវក្នុងការចាក់ចោលសំណល់រឹង ហើយក៏ជាកង្វល់របស់ក្រសួងបរិស្ថាន ដែលកំពុងខិតខំតាក់តែងច្បាប់ សម្រាប់អង្កេតតាមដាន និងត្រួតពិនិត្យការបំពុល អោយមានប្រសិទ្ធិភាព។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មកទល់ត្រឹមនេះ យើងបានដឹងអំពីសារៈសំខាន់នៃការគ្រប់គ្រង កាកសំណល់រឹង និងភាពចាំបាច់ដែលត្រូវរួមធ្វើទាំងអស់គ្នា ប៉ុន្តែប្រជាពលរដ្ឋយើងមួយចំនួនមិនទាន់ដឹងនៅឡើយទេ អំពីការគ្រប់គ្រងកាកសំណល់រឹង នៅរាជធានីភ្នំពេញ ជាពិសេសគឺ ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញសម្រាម និងវិធានការនៃការគ្រប់គ្រង ។ សំណួរក្នុងការស្រាវជ្រាវលើប្រធានបទនេះ បានលើកឡើងថា តើការគ្រប់គ្រងកាកសំណល់រឹងនៅ រាជធានីភ្នំពេញ មានការប្រព្រឹត្តទៅ យ៉ាងដូចម្តេចដែរ? ថាតើមាន បញ្ហាប្រឈម និង ដំណោះស្រាយអ្វីខ្លះ ជាមួយអ្នកពាក់ព័ន្ធដូចជា សាលារាជធានីភ្នំពេញ ក្រុមហ៊ុន ឯកជន ស៊ីនទ្រី និងជាពិសេសគឺប្រជាពលរដ្ឋផ្ទាល់តែម្តង ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងដើម្បីរកអោយឃើញអំពីវិធានការគ្រប់គ្រង កាកសំណល់នៅរាជធានីភ្នំពេញ ក៏ដូចជា ផែនការយុទ្ធសាស្ត្ររបស់សាលារាជធានីភ្នំពេញ ក្នុងការធ្វើអោយប្រជាពលរដ្ឋទទួលបានការអប់រំ និង ចំណេះដឹងទាក់ទងនឹង ការញែក ការវេចខ្ចប់ ការទុកដាក់ និង បញ្ចេញសម្រាមរបស់ពួកគាត់ មិនត្រឹមតែប៉ុណ្ណោះ ឯកសារស្រាវជ្រាវនេះក៏ជាការប្រមូលគ្រប់អ្នកពាក់ព័ន្ធ វិស័យរដ្ឋ វិស័យឯកជន និង ប្រជាពលរដ្ឋផ្ទាល់ អោយមានការចូលរួមយ៉ាងសកម្ម ក្នុងកិច្ចការពារនៅបរិស្ថានរបស់យើងគ្រប់ៗគ្នា ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ គឺធ្វើឡើងនៅតែ រាជធានីភ្នំពេញតែប៉ុណ្ណោះ ដែលត្រូវបានសិក្សាស្រាវជ្រាវ នៅទីចាត់ការគ្រប់គ្រងកាកសំណល់រឹងនៃ សាលារាជធានីភ្នំពេញ វិស័យឯកជន ក្រុមហ៊ុន ស៊ីនទ្រី ( ខាមប៊ូឌា ) និងការ សម្ភាសន៍ផ្ទាល់មាត់ជាមួយប្រជាពលរដ្ឋ សិស្ស និស្សិតដែលរស់នៅទីក្រុងភ្នំពេញ ។ ការសិក្សាស្រាវជ្រាវនេះ គឺស្ថិតនៅក្នុងអាណត្តិទី៥[1] នៃការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ក្នុងឆ្នាំ ២០១៣-២០១៧។

## ៥. សារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ

ចំពោះសារៈប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទនេះនឹងចូលរួមយ៉ាងសំខាន់ក្នុង

[1] រដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៧

ដំណើរការនៃការគ្រប់គ្រងកាកសំណល់នៅរាជធានីអោយកាន់តែមានប្រសិទ្ធិភាព និងជាពិសេសគឺអ្នកជំនាន់ក្រោយនឹងអាចទទួលបានឯកសារ និងចំណេះដឹងកាន់តែទូលំទូលាយ ដើម្បីបំពេញសេចក្តីត្រូវការ ឬក៍អាចជាការជួយបាននូវអ្វីដែលខ្វះខាតនានានៅពេលបច្ចុប្បន្ននេះ ។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ទិន្នន័យដែលប្រមូលបាន គឺមានពីរប្រភេទ ដែលទិន្នន័យទីមួយ ( Primary Data ) និងទិន្នន័យទីពីរ ( Secondary Data ) បូករួមបញ្ចូលគ្នា ដើម្បីបាន សមិទ្ធផលនៃស្នាដៃមួយនេះឡើង ។

- **ទិន្នន័យទីមួយ** ជាប្រភេទទិន្នន័យផ្ទាល់ ( Primary Data ) គឺជាទិន្នន័យដែលបានសាកសួរសំណួរមួយចំនួនទៅកាន់មន្ត្រីដែលបម្រើការងារនៅទីចាត់ការគ្រប់គ្រងកាកសំណល់រឹងនៃសាលារាជធានីភ្នំពេញ និងក៍ដូចជាការសួរសំណួរទៅកាន់ប្រជាពលរដ្ឋ ដែលទាក់ទងនឹងបញ្ហាប្រឈម និងដំណោះស្រាយ ។
- **ទិន្នន័យទីពីរ** ( Secondary Data ) បានមកពីការដកស្រង់ចំពោះខ្លឹមសារសំខាន់ៗ និងចាំបាច់នានា ដែលប្រមូលបានពី ឯកសាររបស់ទីចាត់ការគ្រប់គ្រងកាកសំណល់ លិខិតបទដ្ឋានគតិយុត្តិ ដែលមានជាធរមាន , បណ្ណាល័យនានាក្នុងរាជធានីភ្នំពេញ , គេហទំព័ររបស់សាលារាជធានី , គេហទំព័រ របស់ក្រុមហ៊ុនស៊ីនទ្រី ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណានេះ មានរចនាសម្ព័ន្ធដូចតទៅ ៖

- សេចក្តីផ្តើម
- ជំពូកទី ១ រដ្ឋបាលដែនដី ថ្នាក់រាជធានី
- ជំពូកទី ២ ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញសំរាម និងវិធានការនៃការគ្រប់គ្រងកាកសំណល់
- ជំពូកទី ៣ វិស័យឯកជនលើការគ្រប់គ្រងកាកសំណល់
- ជំពូកទី ៤ បញ្ហាប្រឈម និងដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់
- សន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី១

# រដ្ឋបាលដែនដីថ្នាក់រាជធានី

## ១-១. ទីតាំងភូមិសាស្ត្រ

### ១.១.១. ស្ថានភាពទូទៅ

ភ្នំពេញស្ថិតនៅក្នុងតំបន់ខាងត្បូងកណ្ដាលនៃប្រទេសកម្ពុជានៅចំណុច-ប្រសព្វនៃទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ។ [2]ទន្លេទាំងនេះផ្តល់នូវ ប្រព័ន្ធអេកូឡូស៊ីទឹកសាប និងទន្លេប្រកបដោយសក្តានុពលជាធនធាន ដ៏សំខាន់សម្រាប់លក្ខខណ្ឌ បរិស្ថានប្រកបដោយចីរភាព សោភណភាព ធម្មជាតិ និងវប្បធម៌ប្រកបដោយភាពចម្រុងចម្រើនសម្រាប់ប្រជាជននៅរាជធានី ភ្នំពេញ តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន ។

ភ្នំពេញ ស្ថិតនៅចំពីមុខទន្លេមេគង្គ ដែលជាទន្លេដ៏សំខាន់នៅអាស៊ី មានបណ្តោយប្រវែង៨គីឡូម៉ែត្រ ២០០.២៦១០ ម៉ាយ។ ប្រភពដើមនៃ ( ទន្លេនេះ គឺមកពីតំបន់ខ្ពង់រាបទីបេ ប្រទេសចិន )។ ទន្លេនេះហូរកាត់ប្រទេសកម្ពុជាពីជើងទៅត្បូង មានបណ្តោយ សរុបប្រវែង ៤៨៦ គីឡូម៉ែត្រ ហើយកាត់ភូមិ ៣០២ ម៉ាយ ហើយភូមិសាស្ត្ររាជធានីភ្នំពេញគឺជាចំណុចប្រសព្វទន្លេបួនមុខ ដែលបានបង្កើតបាននូវប្រព័ន្ធអេកូឡូស៊ី និងទឹកសាប ដ៏គួរអោយទាក់ទាញសម្រាប់ រាជធានីភ្នំពេញ ។ រីឯ អាកាសធាតុវិញ មានអាកាសធាតុក្តៅ ពេញមួយឆ្នាំ ដោយគ្រាន់តែមានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ ។ នៅក្នុងរាជធានី កម្រិត សីតុណ្ហភាពមានចាប់ពី ១៨ អង្សារ ដល់ ៣៨ អង្សារ សេ (៦៤ ដល់ ១០០ អង្សារ) និង រដូវត្រូវបានបែងចែក ជា២ គឺរដូវប្រាំង ចាប់ពីខែធ្នូ ដល់ខែ ឧសភា និង រដូវវស្សាចាប់ពីខែ មិថុនា រហូតដល់ខែ វិច្ឆិកា ។

### ១.១.២. រដ្ឋបាលដែនដី

#### ១.១.២.១. ទីតាំងភូមិសាស្ត្ររាជធានីភ្នំពេញ

រាជធានីភ្នំពេញ ជាមជ្ឈមណ្ឌល នយោបាយ សន្តិសុខ សេដ្ឋកិច្ច នឹងសង្គមកិច្ច ដែលមានការអភិវឌ្ឍន៍ ប្រកបដោយចីរភាព និរន្តរភាពលើគ្រប់វិស័យ។ ទីតាំងកណ្តាលនៃរាជធានីភ្នំពេញ គឺវមណីយដ្ឋានវត្តភ្នំ ។ ព្រំប្រទល់ដែលនៅព័ទ្ធជុំវិញ រាជធានីភ្នំពេញ មានខេត្តកណ្តាល ដែលភាគខាងកើត ជាប់ស្រុកខ្សាច់កណ្តាល និង ល្វាឯម ភាគខាងលិច ជាប់នឹងស្រុក កណ្តាលស្ទឹង និង ស្រុក អង្គស្នួល ភាគខាង

[2] វេបសាយសាលារាជធានីភ្នំពេញ Phnompenh.gov.kh

ត្បូង ជាប់នឹងស្រុក កៀនស្វាយ និង ក្រុងតាខ្មៅ រីឯភាគខាងជើង ជាប់នឹង ស្រុកពញាឮ និង ស្រុកមុខកំពូល ។

#### ១.១.២.២. ការបែងចែកមណ្ឌលរដ្ឋបាលដែនដី

រាជធានីភ្នំពេញមានផ្ទៃដី[3] ៦៧,៨៤៦.០០ ហិកតា ដែលបែងចែកជា ក្រុង ១ មាន ខណ្ឌចំនួន ១២ សង្កាត់ចំនួន ១០៥ និងភូមិចំនួន ៩៥៣ភូមិ ។ ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួន ២១នាក់ ក្នុងនោះស្រី ៤នាក់[4] ។ គណៈអភិបាលរាជធានីភ្នំពេញ មានចំនួន ៧នាក់ ក្នុងនោះស្រី ១នាក់ ។ គណៈនាយករដ្ឋបាល សាលារាជធានីភ្នំពេញ មានចំនួន ៦នាក់ ក្នុងនោះស្រី ០នាក់ ។ ទីចាត់ការរដ្ឋបាល មានចំនួន ៣នាក់ មានស្រី ០នាក់ ។ ទីចាត់ការគ្រប់គ្រងកាកសំណល់ មានចំនួន ៣នាក់ ក្នុងនោះស្រី ១នាក់ ។ ការិយាល័យបច្ចេកទេស និង ត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន មានចំនួន ៧នាក់ ក្នុងនោះស្រីចំនួន ៣ នាក់ ។ ការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់ មានចំនួន ៥នាក់ ក្នុងនោះស្រីមានចំនួន ២នាក់ ។

#### ១.១.២.៣. ស្ថានភាពប្រជាជន

រាជធានីភ្នំពេញ មានប្រជាជនរស់នៅចំនួនសរុប ១,៤៦១,៨៥៣ នាក់ ក្នុងនោះស្រីចំនួន ៧៦៦,១១៨ នាក់ ។ រីឯចំនួនប្រជាពលរដ្ឋ អាយុ ១៨ឆ្នាំឡើង មាន ៨៨១, ០២០ ដែលក្នុងនោះ ស្រីមានចំនួន ៤៦៥,៥០៩ នាក់ ។ ក្នុងរាជធានីភ្នំពេញ គិតត្រឹមខែមិថុនា ឆ្នាំ២០១១ មានប្រជាពលរដ្ឋជាមន្ត្រីរាជការចំនួន ២៤ជាបុគ្គលិក កម្មករ២៦%% អ្នកផ្តល់សេវាកម្ម ៣៦ និងកសិករចំនួន១៤% ។

#### ១.១.២.៤. ច្រកទ្វារនៃកំណើនសេដ្ឋកិច្ច

- លិច-កើត ៖ បាងកក-ភ្នំពេញ-ហូជីមិញ (ផ្លូវគោក ផ្លូវដែក ផ្លូវអាកាស)
- កើត-ត្បូង ៖ (កំពង់ផែ)ក្រុងព្រះសីហនុ-ភ្នំពេញ-តំបន់ទន្លេមេគង្គលើ (ផ្លូវគោក ផ្លូវដែក មាគ៌ាទស្សនាមេគង្គ ។ល។)

## ១-២. ការគ្រប់គ្រងកាកសំណល់ថ្នាក់ក្រុង

### ១.២.១. រចនាសម្ព័ន្ធសាលាក្រុង និងសមាសភាពថ្នាក់ដឹកនាំ

[3] តារាងស្ថិតិប្រជាពលរដ្ឋ និងទំហំផ្ទៃដី ឃុំ សង្កាត់សរុប របស់រាជធានីភ្នំពេញ ខេត្ត ទូទាំងប្រទេស ឆ្នាំ២០១៧

[4] រដ្ឋបាលរាជធានីភ្នំពេញឆ្នាំ ២០១៧

តាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកចេញជា រាជធានី -ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ -សង្កាត់[5] ។ រដ្ឋបាលថ្នាក់រាជធានីត្រូវដឹកនាំដោយ[6] អភិបាល រាជធានី ១រូប ក៏ដូចជា អភិបាលរង រាជធានីទី១ ចំនួន ១រូប អភិបាលរង រាជធានីទី២ ចំនួន ១រូប អភិបាលរង រាជធានីទី៣ ចំនួន ១រូប អភិបាលរង រាជធានីទី៤ ចំនួន ១រូប អភិបាលរង រាជធានីទី៥ ចំនួន ១រូប និង អភិបាលរង រាជធានីទី៦ ចំនួន ១រូប ។

អភិបាលរាជធានី ត្រូវបានតែងតាំងឡើង ដោយព្រះរាជក្រឹត្យ ចេញពីព្រះមហាក្សត្រ តាមសំណើរបស់នាយករដ្ឋមន្ត្រី (មាត្រា១៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី)

ដោយផ្អែកលើគោលការណ៍ច្បាប់ អភិបាលរាជធានី ស្ថិតក្នុងក្របខណ្ឌរដ្ឋបាលស៊ីវិល មានន័យថា អភិបាលរាជធានីត្រូវបានតែងតាំងផ្លាស់ប្តូរ ឬ បញ្ចប់ភារកិច្ចទៅតាមការផ្លាស់ប្តូររបស់រដ្ឋាភិបាល ពោលគឺសមត្ថកិច្ចរបស់អភិបាលរាជធានីពាក់ព័ន្ធនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ១.២.២ តួនាទី និង ភារកិច្ច

រដ្ឋបាលថ្នាក់រាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចជា រៀបចំដែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា និង មានការបង្កើត គ្រប់គ្រងនិងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មិនតែប៉ុណ្ណោះមានធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពី ការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន ដោយផ្តោតសំខាន់អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ក្នុងការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន ។

[5] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[6] សៀវភៅរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៧

### ១.២.៣. ទីចាត់ការគ្រប់គ្រងកាកសំណល់

#### ១.២.៣.១. តួនាទី និងភារកិច្ចរបស់ទីចាត់គ្រប់គ្រងកាកសំណល់

ទីចាត់ការគ្រប់គ្រងកាកសំណល់ គឺជាសេនាធិការបស់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីក្នុងការសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗដូចជា កសាងគោលការណ៍ និងវិធានការលើការងារគ្រប់គ្រងកាកសំណល់ និង ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍនានា ដើម្បីលើកកម្ពស់ការគ្រប់គ្រងកាកសំណល់ហើយក៏មាន ការអប់រំផ្សព្វផ្សាយដល់សាធារណៈជន ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមក្នុងការគ្រប់គ្រងកាកសំណល់ ជាងនេះទៅទៀត ទីចាត់ការគ្រប់គ្រងកាកសំណល់ សហការដោះស្រាយវិវាទបរិស្ថានដែលបណ្តាលមកពីកាកសំណល់ និង គ្រប់គ្រងការប្រើប្រាស់ឡើងវិញនិងការកែច្នៃសំរាម ។

#### ១.២.៣.២. ផែនការយុទ្ធសាស្ត្រ និងសកម្មភាពនៃការគ្រប់គ្រងសំណល់[7]

ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និង កំណត់ការទទួលខុសត្រូវ ចាំបាច់ត្រូវដឹង អំពីអ្នកដែលពាក់ព័ន្ធ ក្នុងការដាក់ចេញនូវផែនការដើម្បីអនុវត្តន៍អោយមានប្រសិទ្ធិភាព និង ប្រសិទ្ធិផល មានវិស័យ ឯកជន គឺក្រុមហ៊ុនស៊ីន ទ្រី សាលារាជធានីភ្នំពេញ អាជ្ញាធរមូលដ្ឋាន និង ជាពិសេសប្រជាប្រជាពលរដ្ឋ ។ ដូច្នេះ អ្នកពាក់ព័ន្ធទាំងអស់គឺត្រូវមានផែនការដូចជា ៖

**ក្រុមហ៊ុនស៊ីនទ្រី** ៖ ត្រូវរៀបចំអោយមានផែនការការងារប្រចាំខែ និងផែនការយុទ្ធសាស្ត្រពីសេវាសំអាត ប្រមូលនិងដឹកជញ្ជូនសំណល់រឹងតាមសង្កាត់ ខណ្ឌ និងសង្កាត់ និង ផែនការយុទ្ធសាស្ត្រនេះត្រូវធ្វើសម្រាប់រយៈពេល ២-៣ឆ្នាំ យ៉ាងច្រើន ។ ក្រុមហ៊ុនត្រូវមានគម្រោងផែនការ និងតារាងពេលវេលាប្រមូលសំរាមអោយបានច្បាស់លាស់ ចែកជូនអាជ្ញាធរ និងមន្ទីរជំនាញពាក់ព័ន្ធជ្រាបជាព័ត៌មាន។ ក្រុមហ៊ុនស៊ីន ទ្រី ដើរតួនាទីយ៉ាងសំខាន់ក្នុង រៀបចំកម្មវិធីដឹកជញ្ជូនសំរាម (តាមរថយន្ត និងរទេះអូស) និង កម្មវិធីបោសសំរាមផ្លូវ-ថ្នល់ អោយបានច្បាស់លាស់ ព្រមទាំងផ្សព្វផ្សាយដល់ខណ្ឌ សង្កាត់និងប្រជាពលរដ្ឋអោយបានដឹងគ្រប់ផ្ទះ និងគ្រប់ទីតាំងអាជីវកម្មទាំងអស់ ងាយស្រួលក្នុងការបញ្ចេញសំរាមអោយត្រូវពេលគ្នា និង ត្រូវធ្វើកម្មវិធីបោសសំអាត និងដឹកជញ្ជូនសំណល់រឹង មកសាលារាជធានីភ្នំពេញ និងខណ្ឌ សង្កាត់ ដើម្បី ពិនិត្យមុនធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ។

[7] ផែនការ និងយុទ្ធសាស្ត្រអនុវត្តរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០១៤

ក្រុមហ៊ុនត្រូវអនុវត្តន៍អោយបានតាមកម្មវិធី និងពេលម៉ោងដែលបានដាក់ចេញអោយបានទៀងទាត់ ទាំងរថយន្ត និងរទេះអូសសំរាម គឺធ្វើរៀងរាល់ថ្ងៃ អោយបានគ្រប់ផ្លូវធំ-តូច និងគ្រប់ច្រកឡើងហែម ហើយនឹងត្រូវធ្វើយ៉ាងណាប្រមូលសំណល់រឹងអោយបានអស់ និងស្អាតជាប្រចាំរាល់ថ្ងៃដោយក្រោយការប្រមូល១លើកហើយ ត្រូវមានរថយន្តចល័តប្រមូលតាមក្រោយថែមទៀត ព្រមទាំងមានរទេះអូសសំរាម យកតាមផ្លូវតូចៗ និងច្រកផ្លូវឡើងហែមអោយអស់ កុំអោយមានសល់សំរាម។

ក្រុមហ៊ុនត្រូវរៀបចំឡើងវិញនូវ : រថយន្តដឹកសំរាមអោយបានគ្រប់ចំនួន រទេះអូសសំរាមតាមភូមិនីមួយៗ កម្មករប្រមូលសំរាមមានប្រាក់ខែសមរម្យ ជាមួយការដាក់សម្ភារៈដែលបំរើក្នុងការប្រមូល និងដឹកជញ្ជូនសំរាម អោយបានបានគ្រប់គ្រាន់ទៅតាមសំណូមពររបស់សង្កាត់ និងភូមិនីមួយៗ ហើយមិនត្រឹមតែប៉ុណ្ណោះ ក៏ត្រូវមានការបោសសំអាតផ្លូវថ្នល់នានាក្នុងរាជធានីភ្នំពេញ ត្រូវធ្វើរាល់ថ្ងៃ និងអោយបានស្អាតជាពិសេសផ្លូវចាក់កៅស៊ូរួច ហើយត្រូវកៀរកើប និងអាចម៍ដីតាមដងផ្លូវនិងចិញ្ចើមផ្លូវដែលនៅសល់អោយអស់ និងស្អាតល្អ។ ក្នុងនោះផងដែរ ផែនការសកម្មភាព គឺមានការប្រមូលដឹកជញ្ជូនសំរាម តាមទីផ្សារ តាមសួនច្បារ ត្រូវអោយទៀងទាត់ពេលច្បាស់លាស់ រៀងរាល់ថ្ងៃ និងត្រូវបន្ថែមកំលាំងកម្មករថែមទៀត ទើបការយកសំរាមគ្មានការកកស្ទះ ហើយសុំកុំប្រើប្រាស់គ្រឿងចក្រចូកសំរាមបន្តទៀតធ្វើអោយខូចថ្នល់ ដក់ទឹកស្អុយ ជះក្លិនមិនល្អ ធ្វើអោយប៉ះពាល់ដល់បរិស្ថានទីផ្សារ និងសួនច្បារ។

ក្រុមហ៊ុនត្រូវបង្កើនចំនួនជើងដឹកសំរាម អោយបាន២ដង ក្នុង១ថ្ងៃ គឺពេលព្រឹក និងល្ងាច តាមសួនច្បារ រមណីយដ្ឋាន និងទីកន្លែងកំសាន្តសំខាន់ៗនានា ដោយក្រោយការប្រមូលត្រូវបោសសំអាតអោយបានស្អាតកុំអោយមាននៅសល់កំទេចកំទីសំរាមត្រង់កន្លែងប្រមូល ហើយក៏ត្រូវរៀបចំដូរធុងសំរាមថ្មីនិងដាក់បន្ថែមអោយគ្រប់តាមតម្រូវការ នៅតាមសួនច្បារ រមណីយដ្ឋាន និងទីកន្លែងកំសាន្តនានាក្នុងរាជធានីភ្នំពេញ ជាពិសេសព្យាយាមបង្កើនកន្លែងប្រមូលផ្តុំទុកដាក់រទេះអូសសំរាម និងសំភារៈសម្រាប់បំរើការផ្តល់សេវាអោយបានល្អ កុំដាក់រាយប៉ាយនៅតាមទីសាធារណៈ ដែលធ្វើអោយប៉ះពាល់ដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ និង សណ្តាប់ធ្នាប់សាធារណៈ ដែលក្រុមហ៊ុនត្រូវធ្វើអនុវត្តអោយបាន។ ក្រុមហ៊ុនត្រូវមានយន្តការណ៍ក្នុងការបង្កើតទីតាំងផ្ទេរសំរាមអោយបានត្រឹមត្រូវ ដើម្បីកាត់បន្ថយការយឺតយ៉ាវការកកស្ទះសំរាម ការស្ទះចរាចរណ៍ និងបំបាត់ កុំអោយមានសំរាមរាយប៉ាយ ធ្លាក់ចូលប្រឡាយលូ។

ក្រុមហ៊ុនត្រូវដឹកជញ្ជូនសំណល់រឹងអោយទាន់ពេលវេលាកំណត់ ហើយរទេះអូសសំរាមត្រូវផ្ទេរសំរាមដោយផ្ទាល់ទៅរថយន្តដឹកសំរាមតែម្តង មិនអោយមានដេប៉ូសំរាមបន្តទៀតទេ ធ្វើអោយប៉ះពាល់ខ្លាំងដល់បរិស្ថានក្នុងតំបន់ទាំងនោះ ហើយបើចង់អោយមានការដឹកទាន់ពេលវេលា គឺត្រូវមានបង្កើន

ជើងរថយន្ត និងរទេះអូសសំរាមតាមគ្រប់សង្កាត់ និងគ្រប់ផ្លូវទាំងអស់ (ផ្លូវធំ-តូច) ជាពិសេសត្រូវមាន រថយន្ត ១-៣គ្រឿង ចល័តជាប្រចាំតាមសង្កាត់នីមួយៗនិងរទេះអូសសំរាម១ភូមិ១ (តែចំពោះ សង្កាត់ដែលមានផ្លូវ និងច្រកឌ្រើងហែមច្រើន ១ភូមិ ៣រទេះ) និងព្រមទាំងដាក់អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន ០១នាក់ ងាយស្រួលទំនាក់ទំនងទៅក្រុមហ៊ុនផ្ទាល់ ។ ស្របពេលក្នុងការប្រមូលផងដែរ រថយន្តដឹកសំរាម ត្រូវបើកយឺតៗ និងរកទីតាំងទំនេរឈប់អោយបានញឹកញាប់ ដើម្បីអោយប្រជាពលរដ្ឋអាចយកសំរាមមកដាក់ឡានទាន់ ហើយកម្មករក្រុមហ៊ុនមិនត្រូវកាយសំរាមក្នុងឡានដើម្បីរើសអេតចាយអោយខ្ចាយជ្រុះពេញផ្លូវឡើយ។

ក្រុមហ៊ុនគួរតែមានលេខទូរស័ព្ទសំរាប់ទំនាក់ទំនង (Hot Line) និងអ្នកទទួលខុសត្រូវខ្ពស់ក្នុងការផ្តល់ដំណឹង និងព័ត៌មាន ដើម្បីអោយប្រជាពលរដ្ឋអាចធ្វើការសាកសួរព័ត៌មាន ប្រសិនបើមានការអាក់ខាន ឬគ្មានការប្រមូលសំរាមទាន់ពេលវេលាកំណត់។

សម្រាប់ **សាលារាជធានីភ្នំពេញ** ៖ វិស័យរដ្ឋគឺដើរតួនាទីខ្លាំង ប្រើប្រាស់យន្តការផាកពិន័យដែលមានស្រាប់កន្លងមក និង បង្កើតអោយមានក្រុមផាកពិន័យមួយដែលមានសមាសភាពពីសាលារាជធានីភ្នំពេញ និងមន្ទីរជំនាញពាក់ព័ន្ធដើម្បីចុះពិនិត្យ និងជំរុញការអនុវត្តន៍អោយមានប្រសិទ្ធិភាពជាងបច្ចុប្បន្ន។ សាលារាជធានីភ្នំពេញ ត្រូវមានការពង្រឹងការផាកពិន័យអោយបានម៉ឺងមាត់ ចំពោះអ្នកបោះចោលសំរាមផ្តេសផ្តាសមិនតាមពេលវេលាកំណត់ និងក្រុមហ៊ុនប្រសិនមិនអនុវត្តទៀងទាត់តាមកម្មវិធី និងពេលវេលាកំណត់ និងក្រុមហ៊ុនប្រសិនមិនអនុវត្តន៍ទៀងទាត់តាមកម្មវិធី និងពេលកំណត់ផងដែរ មិនត្រឹមតែប៉ុណ្ណោះ សាលារាជធានីភ្នំពេញត្រូវមានការបែងចែកភារកិច្ចអោយបានច្បាស់លាស់រវាងអ្នកម៉ៅការប្រមូលចំនូលពី ភាស៊ី ផ្សារ ចំណតរថយន្ត និងក្រុមហ៊ុន ស៊ីនទ្រី តើអ្នកណាអ្នកសម្អាត និងប្រមូលសំរាមក្នុងផ្សារ អ្នកណាអ្នកបោសសំអាត និងប្រមូលសំរាមជុំវិញផ្សារ និងតាមចំណតរថយន្តនានា។

សាលារាជធានីភ្នំពេញត្រូវធ្វើការណែនាំ និងដោះស្រាយតាមចំណាត់ការ ព្រមទាំងត្រូវចុះទៅត្រួតពិនិត្យ និងរកវិធានការដោះស្រាយ ចំពោះទីលានចាក់សំណល់ចេញពីរោងចក្រ ដែលធ្វើអោយប៉ះពាល់ដល់ប្រជាពលរដ្ឋ និងបរិស្ថាននៅក្នុងសង្កាត់កំបូល ដែលជាសង្កាត់ថ្មីបានកាត់ចូលក្នុងដែនដីរាជធានីភ្នំពេញ។ ត្រូវមានការណែនាំ និងដោះស្រាយបញ្ហាជាមួយក្រុមហ៊ុន ដែលគ្រប់គ្រងទីលានចាក់សំណល់ចេញពីរោងចក្រ ដើម្បីរៀបចំទីលានអោយបានត្រឹមត្រូវតាមបច្ចេកទេស និងមានបរិស្ថានល្អ ជាពិសេសត្រូវមានការរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ និងកម្មវិធីផ្សេងៗ ទៅលើការយល់ដឹងទូទៅឬផ្តល់ព័ត៌មានអោយបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ ដែលទាក់ទងបញ្ហាគ្រប់គ្រងសំណល់ ហើយអ្វី

ជាចំនុចសំខាន់ក្នុងនោះផងដែរគឺត្រូវមានការណែនាំដោយកំណត់អោយប្រជាពលរដ្ឋមានធុងដាក់សំរាម អោយមានស្តង់ដាត្រឹមត្រូវ សំរាប់ទុកដាក់អោយបានស្អាត និងមានអនាម័យល្អ។

**អាជ្ញាធរមូលដ្ឋាន ខណ្ឌ សង្កាត់ ៖** អាជ្ញាធរមូលដ្ឋានដែល នៅកៀកជាមួយប្រជាពលរដ្ឋគឺជា ភាពទុកចិត្តរបស់ប្រជាពលរដ្ឋ ដែលពួកគាត់អាចពឹងពាក់ ដូច្នេះអាជ្ញាធរមូលដ្ឋាន ដើរតួនាទីស្នូល ដោយធ្វើការត្រួតពិនិត្យទៅលើការសំអាត ការប្រមូល និងការដឹកជញ្ជូន របស់ក្រុមហ៊ុន ស៊ីនទ្រី បើមិនត្រឹមត្រូវតាមកម្មវិធី និងម៉ោងកំណត់ ត្រូវធ្វើការណែនាំ ប្រមាន និងពិន័យ ក៏ដូចជារាយការណ៍ទៅដល់ថ្នាក់លើ អោយមានចំណាត់ការ ក្នុងការដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ។

សម្រាប់ចំនុចសំខាន់នោះគឺ ខណ្ឌ និង សង្កាត់ ត្រូវមានការរាយការណ៍ជាប្រចាំពីស្ថានភាពសំណល់រឹង នៅក្នុងមូលដ្ឋានរបស់ខ្លួនដែលកំពុងប្រឈម និងបានធ្វើការដោះស្រាយ មកសាលារាជធានីភ្នំពេញ មិនត្រូវអោយមានសំរាមឈានទៅដល់ការគរឡើងច្រើននោះទេ ។

សម្រាប់ **ប្រជាពលរដ្ឋ ៖** ភាពទទួលខុសត្រូវ និង ផែនការសម្រាប់អនុវត្តន៍នោះគឺ ការបញ្ចេញ និងទុកដាក់សំណល់អោយបានត្រឹមត្រូវ និងតាមពេលកំណត់ (គួរធ្វើការញែកសំណល់អេតចាយចេញ និងទុកដាក់ដោយឡែក) ដើម្បីកុំអោយមានអ្នករើសសំណល់អេតចាយ ហែកចង់សំរាម ធ្វើអោយខ្ចាយពេញផ្លូវ។

ប្រជាជនដែលមិននៅតាមផ្លូវគោលដៅបោសសំអាតត្រូវទទួលខុសត្រូវបោសសំអាតនៅមុខគេហៈដ្ឋាន និងក្បែរចិញ្ចើមផ្លូវខាងមុខផ្ទះអោយស្អាត និងធានាមិនអោយមានកញ្ចប់សំរាមនៅខាងមុខផ្ទះខុសពេលវេលាដែលបានកំណត់ និងបានផ្សព្វផ្សាយរួច។ ប្រជាពលរដ្ឋគ្រប់រូប ត្រូវមានការរួសរាន់ក្នុងការបញ្ចេញសំណល់អោយទាន់ពេលវេលារថយន្តប្រមូល ចៀសវាងការកកស្ទះចរាចរណ៍ពេលរថយន្តឈប់ចាំ។ ក្នុងករណីមកមិនទាន់រថយន្ត មិនត្រូវទុកសំរាមចោលលើដងផ្លូវចិញ្ចើមផ្លូវ ឬលើទ្រូងផ្លូវឡើយ ព្រោះបង្កអោយមានផលវិបាកនានា។ សម្រាប់ចំពោះសំណល់មែកឈើដែលនៅមុខផ្ទះរបស់ប្រជាពលរដ្ឋ ត្រូវជួយសម្រួលអោយតូច ខ្លី ងាយស្រួលដាក់បញ្ចូលក្នុងឡានសំរាម។ ចំនុចសំខាន់មួយទៀតនោះគឺ ប្រជាពលរដ្ឋត្រូវមានការចូលរួមអនុវត្តតាមការណែនាំរបស់សាលារាជធានីភ្នំពេញ មន្ទីរជំនាញនានា និងអាជ្ញាធរមូលដ្ឋានខណ្ឌ សង្កាត់ និងភូមិ សំដៅកែលំអការគ្រប់គ្រងសំណល់រឹងអោយល្អប្រសើរនៅមូលដ្ឋានរបស់ពួកគាត់។

បន្ទាប់ពីអ្នកពាក់ព័ន្ធទាំងអស់មានផែនការហើយនោះ ចាំបាច់ត្រូវមានភាពសហប្រតិបត្តិការ ក្នុងការជួយកែលម្អអោយមានការការគ្រប់គ្រងកាកសំណល់កាន់តែប្រសើរថែមមួយកំរិតទៀត នោះគឺយើងត្រូវមានការសហការគ្នារវាងស្ថាប័ន និងស្ថាប័នពាក់ព័ន្ធដទៃផ្សេងៗទៀត ដូចជា ៖

**ការសហការណ៍ រវាងក្រុមហ៊ុន ស៊ីន ទ្រី ជាមួយនឹង សាលារាជធានី :** សហការដើម្បីកំណត់ផ្លូវក្នុងការបោសសំអាត និង ការបែងចែកភារកិច្ចអោយដាច់គ្នា និងច្បាស់លាស់ រវាងអ្នកម៉ៅការប្រមូលភាស៊ីក្នុងផ្សារ អ្នកចំណតរថយន្ត និងក្រុមហ៊ុនស៊ីនទ្រី តើអ្នកណាអ្នកសំអាត និងប្រមូលសំរាមក្នុងផ្សារ អ្នកណាអ្នកបោសសំអាត និងប្រមូលសំរាមជុំវិញផ្សារ និងតាមចំណតរថយន្តនានា និងចាំបាច់ត្រូវមានការសហការគ្នាដើម្បីដោះស្រាយក្នុងការបែងចែកភារកិច្ចអោយបានច្បាស់លាស់ ជាមួយគណៈកម្មការផ្សារ អ្នកម៉ៅការភាស៊ីផ្សារ ចំណតរថយន្តជុំវិញផ្សារ និងចំណតនានាផ្សេងទៀត។

**ការសហការណ៍ រវាងក្រុមហ៊ុន ស៊ីន ទ្រី ជាមួយនឹង អាជ្ញាធរមូលដ្ឋាន ខណ្ឌ សង្កាត់ :** អាជ្ញាធរមូលដ្ឋានត្រូវរៀបចំឡើងវិញនូវ ច្បាប់ នឹងលិខិតបទដ្ឋាននានា ពិនិត្យកម្មវិធីផ្តល់សេវារបស់ក្រុមហ៊ុនស៊ីន ទ្រី និងអ្វីដែលក្រុមហ៊ុនបានអនុវត្តខុសពីមុនត្រូវអោយកែប្រែឡើងវិញ ហើយមិនតែប៉ុណ្ណោះ គឺក្រុមហ៊ុន ស៊ីនទ្រីត្រូវមានការសហការគ្នាដើម្បីកែលំអកំហុសដែលមានកន្លងមកផងដែរ ។

**ការសហការណ៍ រវាងក្រុមហ៊ុន ស៊ីន ទ្រី ជាមួយ សង្កាត់ និង ប្រជាពលរដ្ឋ :** នេះជាគឺជាការសហការគ្នាតាមរយៈធ្វើការអប់រំប្រជាពលរដ្ឋជាប្រចាំអោយយល់ដឹងពីការសំអាត ការទុកដាក់ និងបញ្ចេញសំរាមអោយបានត្រឹមត្រូវអោយតាមពេលវេលាកំណត់ និងសិក្សាស្វែងយល់ពីផលប៉ះពាល់ដែលបណ្តាលមកពីសំរាម។ ការសហការគ្នាជាមួយសាលាសង្កាត់នេះផងដែរ គឺដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋតាមរយៈការអប់រំ និងខិតប័ណ្ណផ្សព្វផ្សាយផ្សេងៗ មិនត្រឹមតែប៉ុណ្ណោះក្រុមហ៊ុនស៊ីនទ្រី អាចសហការជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋដើម្បីរៀបចំកម្មវិធីដឹកជញ្ជូនសមស្រប ក្នុងការដឹកជញ្ជូនសំណល់អោយបានទាន់ពេលវេលា។

**ការសហការណ៍ រវាងក្រុមហ៊ុន ស៊ីន ទ្រី ជាមួយ សាលារាជធានីភ្នំពេញ ខណ្ឌ សង្កាត់ និងមន្ទីរ បរិស្ថាន :** ការសហការទៅលើការលប់បំបាត់អោយអស់ការដាក់ធុងសំរាមធំៗ និងធុងកុងតេន័រ លើចិញ្ចើមផ្លូវដងផ្លូវ ទ្រូងផ្លូវ ដែលធ្វើអោយប៉ះពាល់ដល់ការធ្វើចរាចរ និងបង្កអោយមានបញ្ហានានាទៀត ក៏ដូចសហការគ្នាដើម្បីដោះស្រាយក្នុងការបំបាត់ដេប៉ូសំរាម និងគំនរសំរាមនៅរាយប៉ាយតាមដងផ្លូវនានា ជាពិសេសសំរាមចេញពីតាមផ្លូវតូចៗ និងច្រកផ្លូវខឿងហែម ជាងនេះទៅទៀតគឺការសហការគ្នាដើម្បីដោះស្រាយបំបាត់ធុងកុងតេន័រ ដាក់នៅជិតមាត់ប្រឡាយ និងលូ ដែលបង្កអោយមានសំរាម ធ្លាក់ចូល លូប្រឡាយ ធ្វើអោយស្ទះចរន្តទឹកហូរ។

**ការសហការណ៍ រវាងក្រុមហ៊ុន ស៊ីន ទ្រី ជាមួយ មន្ទីរសាធារណការ និងដឹកជញ្ជូន** :ការសហការទៅលើសំណល់នៅតាមសួន និងទីកន្លែងកំសាន្តសាធារណៈផ្សេងៗ ត្រូវតែទុកដាក់អោយបានត្រឹមត្រូវមុនពេលក្រុមហ៊ុនមកប្រមូល ហើយក្រុមហ៊ុនត្រូវពិនិត្យមើលចំនួនធុងសំរាម និងបន្ថែមបរិមាណធុងសំរាមជាប្រចាំដើម្បីទុកដាក់សំរាម អោយបានគ្រប់គ្រាន់ និងកុំអោយរាយប៉ាយនៅតាមសួនច្បារ និងទីកន្លែងសាធារណៈផ្សេងៗ ដែលបណ្តាលអោយប៉ះពាល់ដល់សោភណភាពទីក្រុង ។

**ការសហការណ៍ រវាងក្រុមហ៊ុន ស៊ីន ទ្រី ជាមួយក្រុមហ៊ុន វិនិយោគផ្សារ** : គឺថាតាមផ្សារនីមួយៗ ត្រូវមានកន្លែងស្តុកសំណល់អោយបានត្រឹមត្រូវ ដើម្បីអោយក្រុមហ៊ុនមកប្រមូលតាមពេលវេលាកំណត់ នឹងតាមផ្សារនីមួយៗក៏ត្រូវរៀបចំធុងសំរាមធំៗអោយបានយ៉ាងតិច២ ដែលមាន ចំណុះសមស្រប សំរាប់ទុកដាក់សំណល់សើម និង សំណល់ផ្សេងៗ អោយបានគ្រប់គ្រាន់ ។

**ការសហការណ៍ រវាងសាលារាជធានីភ្នំពេញ និង អាជ្ញាធរមូលដ្ឋាន ខណ្ឌ សង្កាត់** : ការសហការនេះគឺផ្តោតសំខាន់លើការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យការងារ ពីថ្នាក់លើ រហូតដល់ថ្នាក់ក្រោមអោយបានច្បាស់លាស់ ទើបការងារអនុវត្តទៅមានប្រសិទ្ធិភាព និងធ្វើអោយខណ្ឌ សង្កាត់ និងរាជធានីភ្នំពេញបានស្អាត តែយន្តការនេះក៏ត្រូវមានការឧបត្ថម្ភផងដែរ ទើបដំណើរការបានរលូនល្អ និងមាននិរន្តភាព។

**ការសហការណ៍ រវាងសាលារាជធានីភ្នំពេញ និង សង្កាត់ជាមួយ ប្រជាពលរដ្ឋ** : នេះគឺជាការសហការគ្នាក្នុងការទប់ស្កាត់សំណង់ដើម្បីអោយមានច្បាប់សាងសង់ត្រឹមត្រូវ ហើយចំពោះការសាងសង់នោះផងដែរ ត្រូវអោយមានរបងហ៊ុំព័ទ្ធសំណង់ទាំងនោះ ចៀសវាងសំរាមធ្លាក់មកខាងក្រៅ និងត្រូវមានការវេចខ្ចប់សំរាម អោយបានត្រឹមត្រូវ។ រីឯម្ចាស់ដីឡូត៍ទុកនៅទំនេរ ដែលប្រជាពលរដ្ឋយកសំរាមទៅចាក់ត្រូវធ្វើរបងអោយជិត ចៀសវាងទប់ស្កាត់កុំអោយប្រជាពលរដ្ឋយកសំរាមទៅចាក់ បង្កើតជាដេប៉ូសំរាមអាណាធិបតេយ្យ ។ ក្នុងកាលៈទេសៈ មិនសហការគ្នាអនុវត្តន៍ចំណុចទាំងនេះ គឺសង្កាត់ត្រូវមានការដាក់ស្លាកសញ្ញា ការប្រមាន និងការពិន័យ ដែលត្រូវតែធ្វើឡើងចំពោះអ្នកបោះសំរាម ពាសវាល ពាសកាល និងគ្មានសណ្តាប់ធ្នាប់ ។

**ការសហការណ៍ រវាងសាលារាជធានីភ្នំពេញ និង ខណ្ឌ សង្កាត់ ក្រុមហ៊ុន ស៊ីនទ្រី និង អង្គការក្រៅរដ្ឋាភិបាល** : គឺផ្តោតសំខាន់គឺការសហការអំពីអប់រំផ្សព្វផ្សាយ និងផ្តល់តារាងព័ត៌មានអំពីម៉ោងពេលត្រូវប្រមូលសំរាមដល់ប្រជាពលរដ្ឋជាប្រចាំ និងធ្វើការអប់រំ អោយចេះទុកដាក់សំណល់អោយបានល្អ កុំអោយរាយប៉ាយ និងបញ្ចេញ សំណល់អោយទៀងទាត់ពេលវេលា តាមការជូនដំណឹងពីក្រុមហ៊ុន ស៊ីន

ទ្រី និងអាជ្ញាធរមូលដ្ឋាន ជាពិសេសគួរមានការគ្រប់គ្រងការប្រមូលសំរាម សំណល់រឹង និងត្រួតពិនិត្យការងារ ឬសេវាកម្មនេះទៅតាមប្រព័ន្ធបច្ចេកវិទ្យាដូចជា (GPS ) និងធ្វើការត្រូវប្រមូលព័ត៌មានរិះគន់ និងសំណូមពរផ្សេងៗ ដើម្បីកែលំអ ទៅពេលក្រោយ និងអនុវត្តប្រកបដោយប្រសិទ្ធិភាព ។

### ១.២.៤. ការិយាល័យចំណុះទីចាត់ការគ្រប់គ្រងកាកសំណល់

ទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់នៃសាលារាជធានី មានការិយាល័យចំណុះដូចខាងក្រោម ៖

- ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន
- ការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់។

### ១.២.៥. ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន

ការិយាល័យ បច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន ជាសេនាធិការអោយនាយកទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់

### ១.២.៥.១ តួនាទី និង ភារកិច្ច

ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន តួនាទីភារកិច្ចនោះគឺ (ទី១)គ្រប់គ្រងទិន្នន័យកាកសំណល់ ដែលមាននៅក្នុងរាជធានីភ្នំពេញ ជាពិសេស តួនាទីសំខាន់គឺ (ទី២)កសាងផែនការគ្រប់គ្រងកាកសំណល់ទាំងមូលដើម្បីដាក់ចេញជាផែនការសកម្មភាព។ (ទី៣) កសាងគោលការណ៍ និងវិធានការលើការងារគ្រប់គ្រងកាកសំណល់ដើម្បីរុញច្រានអោយផែនការដែលបានដាក់ចេញ និង ការអនុវត្តន៍នោះមានប្រសិទ្ធិភាពខ្ពស់ ។(ទី៤) ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍន៍នានា ដើម្បីលើកកម្ពស់ការគ្រប់គ្រងកាកសំណល់ និងបូក្សរួមអប់រំ ផ្សព្វផ្សាយដល់សាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹង និងចូលរួមគ្រប់គ្រងកាកសំណល់។ (ទី៥) សហការជាមួយអ្នកជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បី ទប់ស្កាត់ដល់ផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីកាកសំណល់ និង ចំនុចសំខាន់គឺតួនាទីក្នុងការដោះស្រាយ វិវាទបរិស្ថាន ដែលបណ្តាលមកពីកាកសំណល់ ។

### ១.២.៦. ការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់

### ១.២.៦.១. តួនាទី និង ភារកិច្ច

ការិយាល័យគ្រប់គ្រងកាកសំណល់ ជាសេនាធិការអោយនាយកទីចាត់ការគ្រប់គ្រងកាកសំណល់ និងមានតួនាទី ភារកិច្ចដូចជា (ទី១) គ្រប់គ្រងទីលានចាក់សំរាម ដែលឡានសំរាមយកទៅចាក់ចោលបន្ទាប់

ពីពួកគេបានប្រមូលរួចរាល់ ( ទី២ ) គ្រប់គ្រងសកម្មភាពផ្តល់សេវាកម្ម និង ប្រមូលដឹកជញ្ជូនសំរាមអោយមានប្រសិទ្ធិភាព ( ទី៣ ) តួនាទី គ្រប់គ្រងការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម ដើម្បីយកការកែច្នៃសំរាមនោះ ទៅប្រើប្រាស់អោយមានប្រយោជន៍ និង( ទី៤ )គ្រប់គ្រងការបូម និងទុកដាក់កាកសំណល់រាវ។

# ជំពូកទី២

# ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញសម្រាម និង វិធានការនៃការគ្រប់គ្រងសម្រាម

## ២-១. ការញែក ការវេចខ្ចប់ និង ការទុកដាក់

### ២.១.១. សមាសភាពអ្នកអនុវត្តរបស់ម្ចាស់សំរាម

សមាសភាពអ្នកអនុវត្តរបស់ម្ចាស់សំរាម គឺសំដៅទៅលើ ប្រជាពលរដ្ឋគ្រប់រូប ដែលនៅតាមមូលដ្ឋាន ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង ដែលមានកាតព្វកិច្ចក្នុងការរក្សាទុកសំរាមរបស់ខ្លួនអោយមានអនាម័យ និងសណ្តាប់ធ្នាប់ ដែលកើតចេញពី កាកសំណល់ម្ហូប សម្ភារៈចាស់ៗ ធូលី ដី ដប កំប៉ុង និង អ្វីៗផ្សេងៗទៀត ដែលសុទ្ធសឹងតែប្រែក្លាយទៅជាសំរាម ដែលប្រជាពលរដ្ឋទាំងអស់គ្នា ត្រូវចូលរួមក្នុងការអនុវត្ត[8] ។

### ២.១.២. ការទទួលខុសត្រូវរបស់អ្នករក្សាការវេចខ្ចប់ ការទុកដាក់

ម្ចាស់សំរាម សំណល់រឹង ត្រូវមានការទទួលខុសត្រូវក្នុងការវេចខ្ចប់ ដោយថង់ ឬ ការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនអោយមានការលេចធ្លាយ មិនត្រូវអោយមានលេចជ្រាបទឹកស្អុយ ឬមិនអោយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំរាម សំណល់រឹង ត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវ កញ្ចប់ ឬធុងផ្ទុកសំរាមសំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានីភ្នំពេញ ក្រុង ស្រុក ខណ្ឌ ។

ម្ចាស់ ឬ អ្នកគ្រប់គ្រងទីតាំងនានា និង បុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្រប សម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួន រង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភណភាពសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ ។

[8] អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជំពូក៣ ទំព័រ៦

### ២.១.២.១. ការបង់ថ្លៃ របស់ម្ចាស់សំរាម

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជន ដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹង ត្រូវមានការបង់ថ្លៃសេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដោយ ក្នុង១គ្រួសារ ត្រូវកាត់ថ្លៃសេវា ចំនួន ៤០០០ រៀល ក្នុងពេលបង់ភ្លើង ប្រចាំខែ ជាមួយអគ្គីសនីកម្ពុជា ។

## ២-២. វិធានការនៃការគ្រប់គ្រងសម្រាម និង ការបង់ប្រាក់ពិន័យលើទោស

### ២.២.១. វិធានការទូទៅ

ក្នុងការរៀបចំវិធានការ ត្រូវបានហាមឃាត់ជាដាច់ខាត នូវការបោះ ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅ តាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹក សាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅអោយអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ មិនតែប៉ុណ្ណោះ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងអោយមានធុងសំរាមសាធារណៈ និងត្រូវមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំអោយមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬ បុគ្គលិករបស់ខ្លួន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអាគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម ៖

- ទុកដាក់អោយបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹង ដែលបណ្តាលមកពី ភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូលនឹងដឹក ជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យាបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹង ដើម្បីដោះស្រាយភាពកកស្ទះ ។

### ២.២.២. វិធានការគ្រប់គ្រង ទីលានទុកដាក់សំរាម

ក្នុងការគ្រប់គ្រង ទីលានទុកដាក់សំរាម ត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់ សំរាម សំណល់រឹងទីប្រជុំជន អោយស្របតាមទីតាំងស្ថានភាព ភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។[9] ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែង សម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន និងត្រូវមានការឯកភាពពីរដ្ឋបាលរាជធានី ។ រាល់គម្រោងស្នើសុំបង្កើតទីលានដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើ បច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ។[10]

ម្ចាស់ ឬ អ្នកគ្រប់គ្រងទីលានទុកដាក់ សំណល់រឹង ត្រូវដំណើរការទីលានរបស់ខ្លួន តាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន ។ បើក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត ។

### ២.២.៣. ការពិន័យ

ក្នុងការមិនអនុវត្តតាមការកំណត់របស់ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជន ដែលអាចប្រើប្រាស់ឡើងវិញឬ កែច្នៃបាន ដូចមានចែង

9 នាយកដ្ឋានគ្រប់គ្រងសំណល់រឹងនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន គោលការណ៍ណែនាំបច្ចេកទេស ឆ្នាំ២០១៦

10 អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជំពូក៦ ទំព័រ១១

ក្នុងមាត្រា១៥ នៃអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម[11] ៖

- ចំនួន ១០.០០០ (មួយម៉ឺន ) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អាគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យ អន្តរការណ៍លើកមុន ។

សម្រាប់បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈ ខុសពេលម៉ោងអនុញ្ញាតអោយធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧ នៃ អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យជាប្រាក់ដូចខាងក្រោម ៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អាគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យ អន្តរការណ៍លើកមុន ។

បុគ្គលដែលបានប្រើប្រាស់សេវា គ្រប់គ្រងសំរាម និងសំណល់រឹង ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាមសំណល់រឹងដែលត្រូវបង់ក្នុងមួយខែ ។

[11] អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ទំព័រ១២

ក្នុងករណីមានបុគ្គលដែលបោះចោលសំរាម សំណល់រឹង នៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹង ទីប្រជុំជន ដែលមានចែងក្នុង មាត្រា ២០ នៃអនុក្រឹតស្តីពី ការគ្រប់គ្រងសំរាម សំណល់ទីប្រជុំជន ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និង ទណ្ឌកម្មដូចខាងក្រោម ៖

- ចំនួន ២០.០០០ (ពីរម៉ឺន)រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋានទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅ ដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវ ទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៨០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន ។

ក្នុងករណី ដែលមានបុគ្គលដុតសំរាម សំណល់រឹង នៅទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា ២០ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្មដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្មសេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន ។

ក្នុងករណីមានបុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹង ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១ ត្រូវទទួលការពិន័យជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម ៖

- ចំនួន ២០០.០០០ (ពីរសែន) រៀលចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងតែបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល
- ចំនួន ២.០០០.០០០ (ពីរលាន)រៀល ចំពោះការប្រគុំតន្ត្រីសាធារណ: ។

ក្នុងករណីដែលមានបុគ្គលដែលធ្វើអាជីវកម្មបូមសំណល់ភក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទឹក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែង ដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា ២៧ ត្រូវទទួលការពិន័យដូចខាងក្រោម ៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណ:គ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណ:ក្រុមហ៊ុន។

ក្នុងករណីមានបុគ្គលដែលមានការធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលការពិន័យ ៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀលសម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជន ។

# ជំពូកទី៣

# វិស័យឯកជនលើការគ្រប់គ្រងកាកសំណល់

## ៣-១. ការគ្រប់គ្រងកាកសំណល់របស់ក្រុមហ៊ុន ស៊ីន ទ្រី ( ខេមបូឌា )

### ៣.១.១. អំពីក្រុមហ៊ុន

ក្រុមហ៊ុន ស៊ីន ទ្រី បានទទួលសិទ្ធិផ្តាច់មុខក្នុងការចុះហត្ថលេខា ដើម្បីធ្វើវិនិយោគលើសេវាកម្មសំអាតប្រមូល និងដឹកជញ្ជូនសំណល់រឹង ( សំរាម ) ពីសាលារាជធានីភ្នំពេញ ចាប់ពីខែសីហា ឆ្នាំ២០០២ ។[12]

### ៣.១.២. រចនាសម្ព័ន្ធ ក្រុមហ៊ុន ស៊ីន ទ្រី

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន ក្នុងនោះមានការិយាល័យសរុបទាំងអស់ចំនួន ៦ ការិយាល័យ រួមមាន ៖

- ការិយាល័យរដ្ឋបាល និងធនធានមនុស្ស
- ការិយាល័យហិរញ្ញវត្ថុ
- ការិយាល័យពត៌មាន
- ការិយាល័យអតិថិជន
- ការិយាល័យសំអាតក្រុង
- ការិយាល័យយានដ្ឋាន និងផ្គត់ផ្គង់ ។

## ៣-២. ចក្ខុវិស័យ និង សកម្មភាពនៃការគ្រប់គ្រងកាកសំណល់

### ៣.២.១. ចក្ខុវិស័យ

ខិតខំបំពេញការងារតាមកាតព្វកិច្ចរបស់ខ្លួន ក្នុងការថែរក្សាបរិស្ថាន និងសោភណភាពរាជធានីភ្នំពេញ ទោះបីមានការចោល និងបញ្ចេញសំរាម ២៤ម៉ោង ឥតឈប់ឈរក៏ដោយ។

[12] ប្រភពពីវេបសាយ ក្រុមហ៊ុន ស៊ីនទ្រី cintri.com.kh

## ៣.២.២. សមិទ្ធផល និងការសម្រេចបានក្នុងការគ្រប់គ្រងកាកសំណល់

### ៣.២.២.១. ការអភិវឌ្ឍរបស់ក្រុមហ៊ុន

ក្នុងការពិនិត្យមើលលើសម្ភារៈនឹងកំលាំងពលកម្មយើងឃើញថា ក្រុមហ៊ុនមានការកើនឡើងរថយន្តប្រមូលសំរាមចំនួន ៤៩គ្រឿង ធៀបនឹងឆ្នាំ២០១៤ និងចំនួន៨១ គ្រឿង ធៀបនឹងឆ្នាំ២០១៣ ចំណែកចំនួន បុគ្គលិក-កម្មករ មានការកើនឡើង ៦៥២នាក់ ធៀបនឹងឆ្នាំ២០១៤ និងសម្ភារៈរទេះសំរាម ក៏មានការកើនឡើង៤៥គ្រឿង ធៀបនឹងឆ្នាំ២០១៤ ធុងដាំស្វ័រ មានការថយចុះ ១៣ធុង ដោយសារក្នុង២០១៥ ទីតាំងមួយចំនួនត្រូវបានដកធុងដាំស្វ័រចេញឈប់អោយមាន ។ ធុងសំរាមដាក់តាមសួនច្បារចាស់ និងថ្មី ថយចុះ ១៣២ធុង ដោយសារធុងសំរាមចាស់ត្រូវបានដកចេញ និងជំនួសដោយធុងសំរាមថ្មី ដែលអាចផ្ទុកសំរាមបានពីរដងនៃធុងសំរាមចាស់។ ធុងបានបោសថយចុះ ៩៨ធុង ដោយសារបង្កើនរទេះប្រើជំនួស ។

**ខាងក្រោមនេះតារាងឧបករណ៍សំភារៈប្រើប្រាស់ និងចំនួនបុគ្គលិក-កម្មករ**[13] :

| ល.រ | ឧបករណ៍សំភារៈ និងកំលាំងពលកម្ម | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|
| 1 | បុគ្គលិក-កម្មករ | 1385 | 1495 | 1553 | 2190 |
| 2 | រថយន្តដឹកសំរាមគ្រប់ខ្នាត | 152 | 161 | 193 | 242 |
| 3 | សាស័រ(គ្រឿងចក្រសំរាប់ចូកសំរាមដេប៉ូធំៗ) | 3 | 5 | 5 | 5 |
| 4 | រថយន្តបោស | 3 | 3 | 5 | 5 |
| 5 | រទេះដឹកសំរាម | 232 | 347 | 216 | 261 |
| 6 | ធុងដាំស្វ័រ | 89 | 121 | 121 | 108 |
| 7 | ធុងស្មាច់ចាស់ + ធុងសំរាមថ្មីដាក់តាមសួនច្បារ | 378 | 419 | 424 | 292 |
| 8 | ធុងសំរាមចំណុះ ១៤០លីត្រសំរាប់កម្មករបោស | 343 | 347 | 417 | 319 |

[13] របាយការណ៍ ក្រុមហ៊ុន ស៊ីន ទ្រី បូកសរុបលទ្ធផល និងទិសដៅការងារ ឆ្នាំ ២០១៦

### ៣.២.២.២. ទំងន់សំរាមដែលក្រុមហ៊ុនដឹកប្រចាំខែ

ក្រុមហ៊ុនអាចប្រមូលសំរាមជាបរិមាណ ៥៥,៨៦៧.២ តោន ក្នុងមួយខែ និងមានកំណើនមធ្យម ស្មើនឹង១៤% ។

| ល.រ | ខែ | ទំងន់សំរាម ( តោន ) | | | ប្រៀបធៀបកំណើនភាគរយ | |
|---|---|---|---|---|---|---|
| | | 2013 | 2014 | 2015 | 2013-2014 | 2014-2015 |
| 1 | មករា | 41719 | 45082 | 56743 | 8% | 26% |
| 2 | កុម្ភៈ | 39314 | 41070 | 53442 | 4% | 30% |
| 3 | មីនា | 31944 | 47682 | 59881 | 14% | 26% |
| 4 | មេសា | 37900 | 43354 | 53518 | 14% | 23% |
| 5 | ឧសភា | 43929 | 49960 | 58787 | 14% | 18% |
| 6 | មិថុនា | 45089 | 51577 | 52847 | 14% | 2% |
| 7 | កក្កដា | 42835 | 49538 | 55524 | 16% | 12% |
| 8 | សីហា | 46766 | 51884 | 57166 | 11% | 10% |
| 9 | កញ្ញា | 44541 | 47632 | 55163 | 7% | 16% |
| 10 | តុលា | 44419 | 55276 | 52096 | 24% | -6% |
| 11 | វិច្ឆិកា | 45332 | 56118 | 54972 | 24% | -2% |
| 12 | ធ្នូ | 43642 | 54932 | 0 | 26% | -100% |

### ៣.២.២.៣. តំបន់សេវា និងការពង្រីកបន្ថែមរបស់ក្រុមហ៊ុន

បច្ចុប្បន្នក្រុមហ៊ុនស៊ីនទ្រី បានគ្របដណ្តប់សេវាសំអាត ប្រមូល និងដឹកជញ្ជូនសំរាម ប្រមាណ ៨០,២% ស្មើនឹង ៧៧សង្កាត់ លើចំនួនសង្កាត់សរុប ៩៦សង្កាត់ (៧៧/៩៦) ក្នុងរដ្ឋបាលរាជធានីភ្នំពេញ ។ ក្នុងខណ្ឌចំនួន ៤ក្នុងរាជធានីភ្នំពេញ (ដូនពេញ ចំការមន ទួលគោក និង៧មករា) ទទួលបាននូវសេវាគ្របដណ្តប់ ១០០% ស្មើនឹង ៤៥សង្កាត់ ហើយ ៨ខណ្ឌ ជាយរាជធានីភ្នំពេញបានទទួលសេវាគ្រប់ដណ្តប់ ១០០% ចំពោះសង្កាត់ដែលមានតម្រូវការប្រមូលសំរាម ព្រមទាំងមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់តែ

ប៉ុណ្ណោះ។ ចំណែកតំបន់សង្កាត់មួយចំនួនផ្សេងទៀត ដែលពុំបានទទួលសេវាដោយសារមិនមានតម្រូវការ និងស្ថាន ភាពទីតាំងនិងគោលដៅ ។

### ៣.២.២.៤. សកម្មភាព និងលទ្ធផលការងារ

ក្រុមហ៊ុនស៊ីនទ្រី បានចូលរួមអនុវត្តការងារជាច្រើនក្នុងរាជធានីភ្នំពេញ ក្នុងគោលបំណងថែរក្សាសោភណភាព និងសំអាតរាជធានី។ សកម្មភាពដែលកើតចេញ សមិទ្ធិផលការងាររួមមាន ៖

1. **ការបង្កើនបរិមាណរថយន្តប្រមូលសំរាម**

   ក្នុងឆ្នាំ ២០១៥ ក្រុមហ៊ុនបានបន្ថែមរថយន្តប្រមូលសំរាមគ្រប់ប្រភេទសរុប ៥៩គ្រឿង ដើម្បីពង្រីកសេវាប្រមូល និងដឹកជញ្ជូនសំរាមបច្ចុប្បន្ន ដើម្បីឆ្លើយតបចំពោះការពង្រីកតំបន់សេវាថ្មី

2. **ការរៀបចំកាលវិភាគថ្មី**

   ក្រុមហ៊ុនបានរៀបចំ និងកែសម្រួលធ្វើបច្ចុប្បន្នភាពកាលវិភាគប្រមូលសំរាមឡើងវិញ តាមខណ្ឌទាំង១២ ក្នុងរាជធានីភ្នំពេញ តាមរយៈការបង្កើនចំនួនជើងប្រមូលឲ្យបានច្រើនជាងមុន ដោយមានការឯកភាពពីសំណាក់អាជ្ញាធរមូលដ្ឋានផងដែរ ។ ជាងនេះទៀតក្រុមហ៊ុនក៏បានធ្វើផែនទីសំគាល់ទីតាំងតំបន់សេវាក្នុងរាជធានីភ្នំពេញទាំងមូល ដើម្បីអោយមានការ ពិនិត្យលើទីតាំងប្រមូលទាំងនោះមានភាពរហ័ស និងសម្រួលពេលវេលា។

3. **គម្រោងភ្ជាប់ GPS តាមរថយន្ត**

   បច្ចុប្បន្នក្រុមហ៊ុនបានធ្វើកិច្ចសន្យាជាមួយនឹងក្រុមហ៊ុន Ovtrast GPS Company Limited ដែលជាក្រុមហ៊ុនផ្តល់នូវសេវាតាមដានរថយន្តតាមរយៈការបំពាក់ GPS ដោយបានបំពាក់ដាក់រថយន្ត ដឹកសំរាមចំនួន ១០០ គ្រឿង ក្នុងរាជធានីភ្នំពេញ ដើម្បីត្រួតពិនិត្យ និងតាមដានសកម្មភាពប្រមូលសំរាមជារៀងរាល់ថ្ងៃ ។

4. **ការរៀបចំផែនការបុណ្យជាតិធំៗ**

   រៀងរាល់កម្មវិធី ឬ បុណ្យជាតិធំៗ ក្រុមហ៊ុនតែងតែរៀបចំផែនការណ៍ និងអនុវត្តន៍ការសំអាតប្រមូលនិងដឹកជញ្ជូនបានយ៉ាងជោគជ័យ ជាក់ស្តែងដូចជា កម្មវិធីបុណ្យចូលឆ្នាំខ្មែរ ភ្ជុំបិណ្ឌ និងបុណ្យអុំទូក ជាដើម។ ក្នុងនោះការជោគជ័យនេះ ក៏អាស្រ័យលើការចូលរួមពីប្រជាពលរដ្ឋ និង អាជ្ញាធរមូលដ្ឋានផងដែរ ក្នុងការជួយសម្រួលគ្នាទៅវិញទៅមក។

5. **ការចូលរួមការងារសង្គម និងការងារខាងក្រៅ**

ក្នុងទស្សនៈចែករំលែក និងសហការគ្នាដើម្បី រាជធានីស្អាត ក្រុមហ៊ុន ស៊ីនទ្រីបានបង្កើត និងចូលរួមសកម្មភាពជាច្រើនក្នុងសង្គម ដើម្បីបើកទូលាយក្នុងការចែកចាយបទពិសោធន៍ផ្សេងៗ ដែលទាក់ទងទៅនឹងការគ្រប់គ្រងសំរាម ការបង្កើតបញ្ជៀបការយល់ដឹងដល់ប្រជាពលរដ្ឋលើផ្នែកបរិស្ថាន ។ ដូចនេះ សកម្មភាពទាំងនោះរួមមានដូចជា ៖ (១)**សហការជាមួយសាលាខណ្ឌពោធិ៍សែនជ័យ ក្រុមហ៊ុន Phnom Penh Tollway និងវិទ្យុប្រជាជន ៖** ចុះចែកខិត្តប័ណ្ណផ្សាយ ពីការទុកដាក់សំរាម ម៉ោងពេលបញ្ចេញសំរាមដល់ប្រជាពលរដ្ឋ (២)**សហការជាមួយសាលាខណ្ឌដូនពេញ ៖** ចុះចែកខិត្តប័ណ្ណផ្សាយ ពីការទុកដាក់សំរាម ម៉ោងពេលបញ្ចេញសំរាមដល់ប្រជាពលរដ្ឋ (៣) **អង្គការយុវជននិស្សិតអន្តរជាតិ អាយស៊ិកភ្នំពេញ ( AIESEC ) :** បានរៀបចំកម្មវិធីជាមួយនិស្សិតអន្តរជាតិ AIESEC និងអ្នកចូលរួមស្ម័គ្រចិត្ត ប្រមាណ៧០នាក់ ដើម្បី បញ្ជ្រាបការយល់ដឹងពី ការគ្រប់គ្រងសំរាម និងសំអាតទីតាំងប្រឈមមួយកន្លែងនៅក្នុងខណ្ឌដូនពេញ ដែលជាទីតាំងបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ គោលដៅសំខាន់គឺចង់ផ្លាស់ប្តូរគំនិត និងយកចិត្តទុកដាក់លើវេចខ្ចប់និងបោះ ចោលសំរាមរបស់ពួកគាត់ ។ (៤) **ការផ្តល់កម្មសិក្សា និងផ្តល់ការពិភាក្សាសម្រាប់និស្សិតសិក្សាក្នុងនិងក្រៅប្រទេស ៖** ក្នុងនោះមាននិស្សិតជាច្រើនបានចូលរួមសិក្សាស្វែងយល់ពីការគ្រប់គ្រងសំរាម ដែលមកពីសាកលវិទ្យាល័យក្នុងនិងក្រៅប្រទេសផងដែរ ។ ក្រុមហ៊ុនបានផ្តល់ឱកាស និងជួយអោយពួកគាត់អាចស្វែងយល់ចំណេះដឹងបន្ថែមជាច្រើនលើការគ្រប់គ្រងសំរាម ហើយកម្មសិក្សានេះក៏ជាប្រយោជន៍ដល់ពួកគាត់ក្នុងការទទួលយកនូវបទពិសោធន៍ថ្មីៗ និងល្អៗផងដែរ មិនត្រឹមតែអាចបញ្ជ្រៀបចំណេះដឹងនោះទេ តែវាជាសកម្មភាពមួយក្នុងការចូលរួមបង្កើតធនធានមនុស្សលើវិស័យគ្រប់គ្រងបរិស្ថានផងដែរ ។

# ជំពូកទី៤

# បញ្ហាប្រឈម និង ដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់

## ៤-១. បញ្ហាប្រឈម

### ៤.១.១. បញ្ហាប្រឈមក្នុងការគ្រប់គ្រងកាកសំណល់នៃសាលារាជធានីភ្នំពេញ

សាលារាជធានីភ្នំពេញមានការព្រួយបារម្ភទៅ លើបញ្ហាប្រឈមនៃបរិមាណសំណល់កើនឡើងជាប្រចាំពីមួយថ្ងៃទៅមួយថ្ងៃ ដែលធ្វើអោយមានការព្រួយបារម្ភយ៉ាងខ្លាំង ទោះបីជាការផ្តល់សេវាកម្មបានល្អ ប្រសើរមួយភាគធំក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមដែលត្រូវយកចិត្តទុកដាក់ដូចជាការប្រើប្រាស់ទីលានចាក់សំរាមជាដើម ជាក់ស្តែងសំរាមដែលត្រូវដឹកជញ្ជូនចេញពីរាជធានីភ្នំពេញយកទៅចាក់នៅទីលាន ចាក់សំរាមដង្កោ បានកើនឡើងពីយ៉ាងខ្លាំងពី ១១០០តោន/ថ្ងៃ (នៅឆ្នាំ២០០៩) ទៅ ១៩៦៥តោន/ថ្ងៃ (ឆ្នាំ២០១៦) ដែលស្ថិតក្នុងអាត្រាកំណើនប្រមាណពី ៨%-១៥% ជារៀងរាល់ឆ្នាំ មិនត្រឹមតែប៉ុណ្ណោះក៏មានបញ្ហាផ្សេងទៀតដូចជា ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកំរិតក្នុងការទុកដាក់សំណល់ ក៏ដូចជាការមិនទាន់យល់ដឹងរបស់ប្រជាពលរដ្ឋទៅលើបទដ្ឋានគតិយុត្តិផ្សេងៗទាក់ទងនិងការគ្រប់គ្រងកាកសំណល់ទាំងនេះផងដែរបានក្លាយជាកង្វល់របស់រដ្ឋាភិបាល ដែលត្រូវយកចិត្តទុកដាក់គ្រប់គ្រងអោយបានហ្មត់ចត់ ទើបអាចបញ្ចៀសបាននូវផលប៉ះពាល់ដល់ បរិស្ថាន សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងសោភ័ណភាពរបស់រាជធានីភ្នំពេញ ។

### ៤.១.២. បញ្ហាប្រឈមក្នុងការគ្រប់គ្រងកាកសំណល់នៃក្រុមហ៊ុន ស៊ីន ទ្រី

ក្នុងពេលប្រតិបត្តិការសំអាត ប្រមូល និងដឹកជញ្ជូន ក្រុមហ៊ុនបានជួបបញ្ហាលំបាកច្រើនក្នុងការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញអោយមានប្រសិទ្ធិភាព បញ្ហាសំខាន់ៗទាំងអស់នោះរួមមាន[14] ៖

#### ក. បញ្ហាលើការងារសំអាត

ជាទូទៅបញ្ហាប្រឈមគឺដោយសារ អ្នកលក់ដូរចល័តតាមផ្លូវសាធារណៈ គ្មានការវេចខ្ចប់

[14] របាយការណ៍ ក្រុមហ៊ុន ស៊ីន ទ្រី បូកសរុបលទ្ធផល និងទិសដៅការងារ ឆ្នាំ ២០១៦

សំរាមរបស់ខ្លួនត្រឹមត្រូវ ដោយពួកគេបានបោះចោលនូវកាកសំណល់ដែលបានពីការលក់ដូរនោះចោល ពាសវាលពាសកាលលើចញ្ចើមផ្លូវ ដែលជាហេតុធ្វើអោយមានការរើ កកាយ ពីសំណាក់អ្នកអេតចាយ ហើយវាធ្វើអោយរប៉ាតរប៉ាយខុសសភាពដើម គ្មានអនាម័យ និងគ្មានសណ្តាប់ធ្នាប់។ លើសពីនេះទៅទៀត រថយន្តដឹកដី ជាប្រភពបញ្ហាមួយរួមចំណែកផងដែរ ដោយសាររថយន្តទាំងនោះ ពុំបានសំអាតកង់អោយស្អាតមុនពេលចរាចរណ៍លើដងផ្លូវ ជាហេតុបណ្តាលអោយជាប់ដីតាមផ្លូវ ហើយខ្លះទៀតពុំមានតង់គ្របដីលើរថយន្ត កត្តានេះធ្វើអោយជ្រុះដី រាយប៉ាយពេញផ្លូវ បង្កបានជាធូលីដីពេលត្រូវខ្យល់បកបោក និងអាចបង្កអោយមានមេរោគផ្សេងៗ ដែលនៅជាប់និងធូលីដីនោះ។ ពិសេសជាងនេះទៅទៀត នៅតាមការដ្ឋានសាងសង់មួយចំនួនធំគ្មានការវេចខ្ចប់សំរាមអោយត្រឹមត្រូវនោះទេ គឺបង្កអោយរាយប៉ាយពាសពេញផ្លូវ និងឥតសណ្តាប់ធ្នាប់ ពិសេសពេលភ្លៀង និងខ្យល់បក់ម្តងៗ។ មួយវិញទៀត រថយន្តដឹកខ្សាច់អោយការដ្ឋានសាងសង់នោះ បង្កអោយមានការជ្រុះ និងមានទឹកហៀរតាមដងផ្លូវ។ល។ បើយើងក្រលេកទៅមើលនៅតាមទីតាំងមួយចំនួនដែលមានសណ្ឋានភាពផ្លូវតូចចង្អៀត និងមានរថយន្តចតនៅតាមផ្លូវ ដែលខ្លះយកទ្រូងផ្លូវជាចំណតរថយន្ត ឬ ម៉ូតូ ទៀតនោះ យើងឃើញថា រថយន្តប្រមូលសំរាមពុំអាចធ្វើដំណើរចូលទៅប្រមូលបានទេ ដែលនេះបង្កអោយមានការកកស្ទះសំរាម និងបញ្ហាជះក្លិនអាក្រក់នៅក្នុងមជ្ឈដ្ឋាននោះផងដែរ។

**ខ. បញ្ហាលើការងារប្រមូលនិងដឹកជញ្ជូន**

ផ្សារមួយចំនួននៅមិនទាន់មានធុងដាំស្ទ័រសម្រាប់ផ្ទុកសំរាម (សំរាមផ្សារ ) ដែលធ្វើអោយសំរាមនៅតែបន្តចោលនៅមុខផ្សារ ឬផ្លូវក្បែរផ្សារដែលបង្កភាពអនាធិបតេយ្យ និងអាចបង្កើតបានជាដេប៉ូសំរាមនៅទីនោះផងដែរ។ មួយវិញទៀតផ្សារខ្លះ គ្មានទីតាំងសម្រាប់ផ្ទុកធុងដាំស្ទ័រ នេះជាផលវិបាកក្នុងការទុកដាក់សំរាមរបស់រទេះ ដែលបានប្រមូលសំរាមបញ្ចេញខុសម៉ោង ឬ ខុសកម្មវិធីប្រមូល និងរទេះអូសសំរាមដែលប្រមូលចេញពីផ្លូវឡើងហែម។ ចំណែកឯធុងសំរាម និងរទេះអូសសំរាម ដែលបានដាក់នៅតាមសួនច្បារ និងទីសាធារណៈ ត្រូវបានជនខិលខូចវាយបំផ្លាញ និងលួច ធ្វើអោយគ្មានធុងសម្រាប់ដាក់សំរាម។ បន្ថែមលើនេះ បញ្ហាអ្នកចោលសំរាមខ្លះបញ្ចេញសំរាមខុសម៉ោងពេល និងខុសគោលដៅធ្វើអោយមានផលវិបាកក្នុងការសំអាត និងប្រមូល បើទោះបីមានកម្មករច្រើនយ៉ាងណាដោយ មិនអាចប្រមូលអោយអស់ដែរ។ បញ្ហាការចតរថយន្តគ្មានសណ្តាប់ធ្នាប់តាមសងខាងផ្លូវ ផ្លូវមួយចំនួនងងឹតដោយគ្មានភ្លើងបំភ្លឺផ្លូវពេលយប់ និងបញ្ហាអសន្តិសុខ ជាហេតុធ្វើអោយការងារប្រមូលសំរាមនៅពេលយប់ជួបការលំបាកច្រើន។ បើនិយាយពីហេដ្ឋារចនាសម្ព័ន្ធផ្លូវ

មួយចំនួននៅតាមជាយរាជធានីភ្នំពេញនៅមានកំរិត ដែលបង្កអោយមានបញ្ហាលំបាកដល់ផ្នែកសេវាប្រមូល និងដឹកជញ្ជូន។ ពេលយប់អ្នកបើកបរស្រវឹងច្រើន ដែលអាចបង្កគ្រោះថ្នាក់ដល់កម្មករដែលកំពុងបំរើការងារប្រមូលសំរាម។

### ៤.១.៣. បញ្ហាប្រឈមក្នុងការគ្រប់គ្រងកាកសំណល់របស់ប្រជាពលរដ្ឋ

សម្រាប់បញ្ហាប្រឈមរបស់ ប្រជាពលរដ្ឋខ្មែរទាក់ទងនឹងការគ្រប់គ្រងកាកសំណល់នៅក្នុងរាជធានីភ្នំពេញ គឺត្រូវបានធ្វើការសាកសួរប្រជាពលរដ្ឋ និង និស្សិតដែលកំពុងរស់នៅរាជធានីភ្នំពេញ នៅមូលដ្ឋានរបស់គាត់ ហើយប្រជាពលរដ្ឋគាត់បានលើកឡើងអំពីបញ្ហាប្រឈមទៅលើកាកសំណល់សំរាម[15] យ៉ាងដូចនេះថា៖ ទីតាំងសម្រាប់អោយពួកគាត់ទុកដាក់ពុំមានគ្រប់គ្រាន់ដែលធ្វើអោយប្រជាជនពុំអាចយកទៅដាក់ដោយផ្ទាល់បាន ហើយពេលខ្លះពុំមានការប្រមូលសំរាមបានទៀតទាត់ដែលវាបណ្តាលអោយសំរាមស្អុយរលួយ បង្កជាបាក់តេរីធ្វើអោយប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋនៅក្បែរនោះ។ កង្វះនៃការយល់ដឹងរបស់ខ្លួនដែលជាប្រជាពលរដ្ឋផ្ទាល់ទៅលើការការគ្រប់គ្រងសំរាម ការបែងចែករវាងសំរាមស្ងួត និង សើម រួមនឹងភាពខ្ជិលរបស់គេទៅលើការទុកដាក់សំរាម ដោយមិនទទួលខុសត្រូវលើសំរាមរបស់ខ្លួនធ្វើអោយគាត់បោះចោលប្រឋល់គ្នា ហើយសំរាមដែលប្រមូលបាននោះពុំយកទៅកែច្នៃដែលចេះតែចាក់ចោលនៅកន្លែងចាក់ធ្វើអោយប៉ះពាល់ដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមផងដែរ។ ហើយអ្វីដែលសំខាន់នោះគឺអាកប្បកិរិយារបស់ប្រជាពលរដ្ឋមិនសូវល្អ ដោយការគប់ និង ក្រវែងចោលសំរាមពាសវាល ពាសកាល ជាបញ្ហាមួយដែរ ទាំងនេះអាចបណ្តាលមកពី វិធានការច្បាប់មានការធូរលុង ចំពោះជនដែលចោលសំរាមផ្តេសផ្តាស ជាពិសេសកន្លែងសួនច្បារសាធារណៈ រមណីយដ្ឋាន។ បន្ថែមលើនេះទៀតគឺកង្វះព័ត៌មានពីការប្រមូលសំរាម សេវាប្រមូលសំរាមមានការយឺតយាវ កង្វះឧបករណ៍សម្រាប់ទុកដាក់សំរាម និងការផ្សព្វផ្សាយអំពីបញ្ហាសំរាមនៅមានកំរិតតិចតួច ដែលធ្វើអោយប្រជាពលរដ្ឋមិនសូវបានសហការចូលរួមការពារ និងទប់ស្កាត់នូវបញ្ហានេះ ធ្វើអោយសំរាមរាយប៉ាយ និង ស្អុយនៅកន្លែងដាក់សំរាម។

---

[15] ការសម្ភាសន៍ ប្រជាពលរដ្ឋដែលរស់នៅទីក្រុងភ្នំពេញ ទាំង១២ខណ្ឌ ខែមិថុនា ឆ្នាំ២០១៧

## ៤-២. ដំណោះស្រាយ

### ៤.២.១. ដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់នៃសាលារាជធានីភ្នំពេញ

សម្រាប់វិធានការដោះស្រាយលើការងារគ្រប់គ្រងកាកសំណល់[16]នៅរាជធានីភ្នំពេញ គឺចាំបាច់ត្រូវមានការរៀបចំ ផែនការណែនាំ អនុវត្តក្នុងការញែកសំរាមនិងផាកពិន័យចំពោះការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់តាមទីផ្សារ ទីសាធារណៈ ក្នុងរាជធានីភ្នំពេញ ហើយជាពិសេសក៏ត្រូវមានការចេញគោលការណ៍ណែនាំពីការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ដើម្បីអោយប្រជាពលរដ្ឋយល់ថា ការប្រើប្រាស់ថង់ប្លាស្ទិកច្រើន វាអាចធ្វើអោយប៉ះពាល់ដល់បរិស្ថាន និង ពោរពេញទៅដោយសំរាម ។

សាលារាជធានីភ្នំពេញត្រូវមានការដោះស្រាយ តាមរយៈការរៀបកម្មវិធី ផ្សព្វផ្សាយ អប់រំ សិក្ខាសាលា ស្តីពី ការកំណត់ភារកិច្ច និងយុទ្ធសាស្ត្រកែលំអការអនុវត្តន៍ ក្នុងការងារគ្រប់គ្រងនិងការផ្តល់សេវាសំអាត និងដឹកជញ្ជូនសំរាម សំណល់រឹង។ មិនតែប៉ុណ្ណោះសាលារាជធានីត្រូវធ្វើការងារទំនាក់ទំនងជាមួយស្ថាប័ន ពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍនានា លើកកម្ពស់ការគ្រប់គ្រងសំណល់អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់ ក្នុងនោះផងដែរក៏ត្រូវមានការរៀបចំប្រព័ន្ធនៃការគ្រប់គ្រងទីលានចាក់សំរាម អោយបានត្រឹមត្រូវនឹងតាមស្តង់ដា ។

សាលារាជធានីភ្នំពេញក៏ត្រូវមានការត្រួតពិនិត្យទៅលើការគ្រប់គ្រងសកម្មភាពផ្តល់សេវាកម្ម និងប្រមូលដឹកជញ្ជូនសំណល់រឹង ដែលបានប្រគល់សិទ្ធិទៅអោយក្រុមហ៊ុនឯកជន និងស្ថាប័នមួយចំនួននៅរាជធានីភ្នំពេញ ដើម្បីកុំអោយមានការធ្វើការមិនគោរពពេលវេលាច្បាស់លាស់ ជាងនេះទៅទៀត ក៏ត្រូវមានការរៀបចំប្រព័ន្ធការងារគ្រប់គ្រងនិងការប្រើប្រាស់ឡើងវិញទៅលើការកែច្នៃសំរាម ដើម្បីយកទៅប្រើប្រាស់អោយមានប្រយោជន៍ដូចជាការយកទៅធ្វើ ជីកំប៉ុស្តិ៍ និងចំណីសត្វជាដើម ។

### ៤.២.២. ដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់របស់ក្រុមហ៊ុន ស៊ីនទ្រី

សម្រាប់ទិសដៅក្នុងដោះស្រាយនាពេលអនាគត គឺក្រុមហ៊ុនមានគម្រោងសិក្សា និងអនុវត្តការងារមួយចំនួន អោយមានភាពកាន់តែប្រសើរឡើង និងដើម្បីកាត់បន្ថយបញ្ហាដែលកើតមានចំពោះមុខក្នុងនោះរួមមានចំនុចដូចជាត្រូវធ្វើផែនការស្តី អំពីការប្រមូល និងដឹកជញ្ជូនសំរាមក្នុងរាជធានីភ្នំពេញ

[16] កម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានីភ្នំពេញ ឆ្នាំ២០១៧-២០១៩

ទាំងមូល ហើយក៏ត្រូវមានការសិក្សាគម្រោងទៅលើទីតាំង ដើម្បីរៀបចំការសាងសង់ទីតាំងផ្ទេរសំរាមខ្នាតតូច ។ ក្រុមហ៊ុន ស៊ីនទ្រីក៏ត្រូវបន្តការទិញរថយន្តប្រមូលសំរាមដើម្បីបំពេញតំបន់ដែលត្រូវពង្រីកសេវាបន្ថែម និងជាភាពងាយស្រួលទៅដល់ដំណើរការនៃការអនុវត្តន៍របស់ខ្លួនផងដែរ ។ ជាងនេះទៅទៀត ត្រូវមានការសិក្សាអំពីលទ្ធភាពកែច្នៃសំរាម ដើម្បីកាត់បន្ថយបរិមាណសំរាមចូលទីលាន (ជីកំប៉ុស្តិ៍) ហើយអ្វីដែលយើងចង់អោយមានការដោះស្រាយនោះគឺ ក្រុមហ៊ុនត្រូវបន្តបន្ថែមធុងសំរាមគ្រប់ប្រភេទ តាមទីសាធារណៈនានាក្នុងការផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋចោលសំរាមអោយមានសណ្តាប់ធ្នាប់ និងមិនបោះចោលពាសវាលពាសកាល ។

ក្រុមហ៊ុន ស៊ីនទ្រី ត្រូវបន្តចុះត្រួតពិនិត្យលើភូមិសាស្ត្របោសសំអាត ប្រមូល និងដឹកជញ្ជូន ដើម្បីកែប្រែលក្ខណៈ បច្ចេកទេសអោយសមស្របជាមួយទម្លាប់ប្រជាពលរដ្ឋ និងភូមិសាស្ត្រនៃសង្កាត់នីមួយៗ ហើយក៏ផ្សារភ្ជាប់ជាមួយនឹងការចូលរួមបង្កើតកម្មវិធី បញ្ជ្រៀបការយល់ដឹងជាសាធារណៈពីការគ្រប់គ្រងសំរាម ដល់ប្រជាពលរដ្ឋ តាមរយៈការអប់រំ និងផ្សព្វផ្សាយផ្សេងៗ ក្នុងនោះក៏មានផ្តល់កម្មសិក្សាដល់សិស្សានុសិស្ស និងនិស្សិតតាមស្ថាប័ននានា ដើម្បីអោយមានឱកាសក្នុងការទទួលយកចំណេះដឹង អំពី ការគ្រប់គ្រងកាកសំណល់ និងជួយផ្នែកមួយក្នុងការជួយបណ្តុះបណ្តាលធនធានមនុស្សអោយយល់ពីសារៈសំខាន់នៃបរិស្ថានផងដែរ ។

### ៤.២.៣. ដំណោះស្រាយក្នុងការគ្រប់គ្រងកាកសំណល់របស់ប្រជាពលរដ្ឋ

វិធីប្រសើរ និងអាចជាដំណោះស្រាយរបស់ប្រជាពលរដ្ឋដែលកើតចេញពីការសាកសួរផ្ទាល់ទៅកាន់ប្រជាពលរដ្ឋដែលគាត់រស់នៅរាជធានីភ្នំពេញ នោះគឺថាត្រូវមានការអប់រំប្រជាពលរដ្ឋអោយចេះបែងចែកសំរាមអោយតាមប្រភេទត្រឹមត្រូវ ទៅលើសំរាមដែលមានប្រយោជន៍ និងសំរាម ដែលអាចលក់វិញបាន ព្រោះថាកាលណាគាត់យល់ដឹងកាន់តែច្បាស់ គឺការគ្រប់គ្រងសំរាមរបស់គាត់នឹងកាន់តែមានភាពល្អប្រសើរ ដូច្នេះការផ្តល់សេវាប្រមូលកាន់តែមានភាពប្រសើរឡើងដែរ ។ មួយវិញទៀតប្រជាពលរដ្ឋត្រូវមានការរៀបចំអោយមានកន្លែងចាក់សំរាម របស់ខ្លួនផ្ទាល់ ជៀសវាងការដាក់សំរាមចោលពេញទីសាធារណៈ ជាងនេះទៀតប្រជាពលរដ្ឋត្រូវដើរតួនាទីសំខាន់នោះគឺឆ្លៀតពេលក្នុងមការចូលរួមជាមួយ ក្រុមហ៊ុន និងអាជ្ញាធរដើម្បីធ្វើការងារប្រមូលសំរាមអោយមានប្រសិទ្ធភាព មិនត្រឹមតែប៉ុណ្ណោះ ប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ត្រូវមានការបណ្តុះកូនចិត្តអោយចេះស្រលាញ់បរិស្ថាន និងភាពស្អាត ផងដែរ ។

ប្រជាពលរដ្ឋត្រូវមានការសិក្សាអោយយល់ពីវិធានការច្បាប់ និង អោយដឹងពីការផាកពិន័យទៅដល់អ្នកដែលប្រព្រឹត្តិខុស ដើម្បីជាផ្នែកមួយក្នុងការបង្ការខ្លួនឯងកុំអោយប្រព្រឹត្តិខុសពីវិធានដែលបានចែង ។ ក្នុង

ពេលបច្ចុប្បន្ននេះ ដើម្បីដោះស្រាយបញ្ហាការគ្រប់គ្រងកាកសំណល់ផងដែរ ប្រជាពលរដ្ឋត្រូវមានការចូលរួមផ្សព្វផ្សាយព័ត៌មាន អំពីបរិស្ថាន សំរាមអោយប្រជាពលរដ្ឋដទៃផ្សេងទៀតបានយល់ដឹង អោយកាន់តែច្រើន តាមរយៈប្រព័ន្ធសង្គមតាមអ្វីដែលយើងអាចធ្វើបាន ក្នុងការធ្វើដូចនេះ វាអាចមានប្រសិទ្ធិភាពខ្ពស់ ពីព្រោះនេះការជាផ្សព្វផ្សាយតាមរយៈអនឡាញ ហើយប្រជាពលរដ្ឋសព្វថ្ងៃក៏មានការប្រើប្រាស់បណ្តាញសង្គមក៏កាន់តែច្រើន ដូច្នេះការបញ្ជៀបព័ត៌មាននេះ អាចទទួលបានលឿនទៅដល់ពួកគាត់ ។

ដំណោះស្រាយផ្សេងទៀតក្នុងការគ្រប់គ្រងកាកសំណល់ មានជាច្រើនទៀតដូចជា ការប្រើប្រាស់សំរាមរបស់ខ្លួនអោយអស់លទ្ធភាពទើបចោលសំរាម ការប្រើប្រាស់ឡើងវិញ មានរបស់របរខ្លះគឺអាចយកទៅប្រើប្រាស់ឡើងវិញ ដោយលាងសំអាត ដូចជា ធុង ដប ហើយព្យាយាមសិក្សាពីការកែច្នៃសំរាមដើម្បីយកទៅប្រើប្រាស់អោយមានប្រយោជន៍ អ្វីដែលជាចំនុចផ្សេងទៀតគឺត្រូវបង្កើតអោយមានឧបករណ៍ទុកដាក់សំរាមក្នុង សហគមន៍ ឬ ភូមិរបស់យើងសម្រាប់ជាកន្លែងមួយ ទុកដាក់ នឹងងាយស្រួលដល់ ក្រុមហ៊ុន ស៊ីន ទ្រី ពេលដែលប្រមូលគឺយកតែមួយដង គឺអស់តែម្តង ។

ប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ចាំបាច់បំផុតគឺ ត្រូវមានការកាត់បន្ថយ ឬ លុបបំបាត់ចោលការប្រើប្រាស់ប្លាស្ទិក ដូចជា ថង់ជាដើម ប៉ុន្តែយើងអាចប្រើប្រាស់ជាកន្ត្រកយួរ ឬការខ្ចប់ដោយការប្រើប្រាស់ស្លឹកឈូក ឬ អ្វីផ្សេងៗទៀត អោយតែខុសពីថង់ប្លាស្ទិក ។

ប្រជាពលរដ្ឋគួរជំរុញ សាលារាជធានីភ្នំពេញ ឬ ក្រុមហ៊ុនឯកជន អោយមានការបង្កើតកម្មវិធីប្រកួតប្រជែង តាមបណ្តារាជធានីខេត្តទាក់ទងទៅនឹងការធ្វើអោយតំបន់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្អាត មានអនាម័យ គ្មានសំរាម និងជាភាពគំរូដាច់គេផងដែរ ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាទៅការគ្រប់គ្រងកាកសំណល់នៅរាជធានីភ្នំពេញរួចមក យើងឃើញថា រាជធានីភ្នំពេញ កំពុងស្ថិតនៅក្នុងកាលៈទេសៈដ៏សែនមានសារៈសំខាន់នៃប្រវត្តិសាស្ត្ររបស់ខ្លួន។ ដោយសារការយឺតយ៉ាវក្នុងអភិវឌ្ឍ បានធ្វើអោយរាជធានីភ្នំពេញអាចរៀនសូត្របានច្រើនពីបទពិសោធន៍ និងកំហុសឆ្គងទាំងឡាយក្នុងការរៀបចំទីក្រុងអោយបានត្រឹមត្រូវ និងប្រកបដោយចីរភាព។ ក្នុងការគ្រប់គ្រងកាកសំណល់ គឺចាំបាច់ត្រូវតែមានការចូលរួមពីអ្នកដែលពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ដូចជាវិស័យរដ្ឋ ឯកជន និង ប្រជាពលរដ្ឋផ្ទាល់ ក្នុងការធ្វើយ៉ាងណាអោយមានការថយចុះនៃកំណើនកាកសំណល់នៅក្នុងរាជធានីភ្នំពេញ។ យ៉ាងណាមិញ ភាគីរដ្ឋគឺត្រូវដើរតួនាទីយ៉ាងសំខាន់ ក្នុងចូលរួមសម្របសម្រួល និងតាមដាននៃការអនុវត្តរបស់អ្នកផ្តល់សេវា ប្រមូលសំរាមទៅកាន់ប្រជាពលរដ្ឋនិងអ្នកដែលទទួលសេវា គឺប្រជាពលរដ្ឋផ្ទាល់ ។ ក្នុងកាលៈទេសៈ មានមានបញ្ហាប្រឈមក្នុងមូលដ្ឋាន ត្រូវមានការសម្របសម្រួល ដោយអ្នកដែលមានសមត្ថកិច្ច ក្នុងការដោះស្រាយ កុំអោយមានការកកស្ទះ និងឈានទៅដល់កើតមានផលប៉ះពាល់នៃបរិស្ថានកាន់តែខ្លាំងឡើងថែមជាមុន ។

ឆ្លងកាត់បទពិសោធន៍ ក្នុងការគ្រប់គ្រងកាកសំណល់ របស់សាលារាជធានីភ្នំពេញ យើងឃើញថា សាលារាជធានីបានសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងការរៀបចំផែនការ និងគោលការណ៍ណែនាំអនុវត្តមួយចំនួន សំដៅអោយមានការគ្រប់គ្រងប្រកដដោយប្រសិទ្ធិភាព និង និរន្តរភាពបរិស្ថាន ដូចជា ការរៀបចំផែនការណែនាំនឹងអនុវត្តក្នុងការញែកសំរាម ការអប់រំប្រជាពលរដ្ឋ ការរៀបចំក្បួនយុទ្ធនាការអប់រំផ្សព្វផ្សាយ ការរៀបចំស្តូតអប់រំ ការរៀបចំសិក្ខាសាលា ការដាក់ចេញគោលការណ៍ណែនាំ អោយប្រើប្រាស់ថង់ប្លាស្ទីក និងមានជាច្រើនទៀតក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង ផ្សេងៗទៀតនៃក្រសួងទេសចរណ៍ បរិស្ថាន -ល- ។ ក្នុងទិសដៅសកម្មភាពនាពេលបច្ចុប្បន្ននៃការគ្រប់គ្រងកាកសំណល់គឺធ្វើយ៉ាងណាយកសំរាមចេញអោយអស់ និងរក្សាសោភណភាព អនាម័យ និងឈានទៅធ្វើការញែកសំរាម កែច្នៃសំណល់ សំរាលការផ្ទុកសំរាមនៅ ទីលានចាក់សំរាមដែលកំពុងកើតមានបញ្ហាផលប៉ះពាល់បរិស្ថាន គំរាមកំហែងប្រជាពលរដ្ឋ ហើយធ្វើយ៉ាងណាត្រូវមានការចូលរួមធ្វើកិច្ចអន្តរាគមន៍របស់អាជ្ញាធរមូលដ្ឋានទៅក្នុងដំណើរការសេវាកម្មដែលកត្តាមួយមិនអាចខ្វះបានឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ត្រូវមានការយកចិត្តទុកដាក់លើចំនុចសំខាន់មួយទៀតដូចជា ការបញ្ចេញសំណល់គ្រោះ ថ្នាក់ចេញពីបរិវេណរោងចក្រ ដោយពុំបានធ្វើប្រព្រឹត្តកម្មតាមស្តង់ដា បានបង្កអោយមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋ ដូច្នេះចាំបាច់ត្រូវមានយន្តការត្រួតពិនិត្យតាមដានជាប្រចាំ

រកអោយឃើញនូវហេតុប៉ះពាល់បរិស្ថាន ដើម្បីចាត់វិធានការធ្វើការដោះស្រាយអោយបានទាន់ពេលវេលា ។

នៅក្នុងនោះផងដែរយើងឃើញមានការចូលរួមយ៉ាងសកម្មរបស់ក្រុមហ៊ុនឯកជន នោះគឺក្រុមហ៊ុន ស៊ីន ទ្រី ដែលជាក្រុមហ៊ុន ផ្តល់សេវាប្រមូលសំរាម ក្នុងរាជធានីភ្នំពេញ។ ក្រុមបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើយ៉ាងអោយអោយការប្រមូលសំរាមក្នុងទីក្រុងមានភាពស្អាត និង ពោរពេញដោយសោភណភាព ។ ឃើញថា ពី ១ឆ្នាំ ទៅ ១ឆ្នាំ ក្រុមហ៊ុនស៊ីនទ្រី បានធ្វើការកែប្រែ និងកំណែទម្រង់ច្រើន ជាពិសេសគឺការកំណែទម្រង់កាលវិភាគ ក្នុងការប្រមូលសំរាម ធ្វើយ៉ាងណា ប្រមូលសំរាមជូនប្រជាពលរដ្ឋអោយទាន់ពេលវេលា ពីព្រោះថា មានការរិះគន់ និង លើកជាបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋច្រើន ក្នុងការយឺតយ៉ាវ នៃសេវាប្រមូលសំរាមរបស់ ស៊ីនទ្រី ។ អាស្រ័យដែលអាចធ្វើអោយការគ្រប់គ្រងកាកសំណល់ក្នុងរាជធានីភ្នំពេញកាន់តែមានការប្រសើរឡើងជាងមុន បន្ទាប់ពីមានការចូលរួម ពី សាលារាជធានី ភ្នំពេញ និង វិស័យឯកជនដោយ តែចំនុចចាំបាច់មួយទៀតនោះ គឺការចូលរួមពីប្រជាពលរដ្ឋ ខ្លួនឯងផ្ទាល់ដែលជាអ្នកទទួលសេវា ។ ប្រជាពលរដ្ឋ គឺដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រងកាកសំណល់ សំរាម នៅក្នុងលំនៅដ្ឋាន របស់គាត់ ដោយតាមរយៈការចេះញែកសំរាម អោយដាច់ដោយឡែកពីគ្នា កុំអោយមានច្រលូកច្រលំ គ្នារវាង សំរាម សើម និង រឹង ។ មិនត្រឹមតែប៉ុណ្ណោះ ប្រជាពលរដ្ឋត្រូវមានសីលធម៌មួយដែលមានទំនួលខុសត្រូវ ក្នុងការធ្វើជាគំរូ ទាក់ទងនឹងការទុកដាក់កាកសំណល់ សំរាម អោយមានអនាម័យ និងមានសណ្តាប់ធ្នាប់ខ្ពស់ ។

ដូច្នេះឆ្លងកាត់ការស្រាវជ្រាវ អំពីការគ្រប់គ្រងកាកសំណល់រឹងនៅរាជធានី ភ្នំពេញ គឺអាចសរុបបានថា ភាគីផ្នែករដ្ឋ ដែលមានសាលារាជធានី ជាតំណាង ក្រុមហ៊ុន ឯកជន ស៊ីន ទ្រី និង ប្រជាពលរដ្ឋ គឺពិតជាមានការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ហើយក៏ចេះកែប្រែនៅចំណុចអវិជ្ជមាន ឬ ភាពអសកម្ម ដោយកាន់តែល្អប្រសើរជាងមុន ដើម្បីធ្វើអោយកាកសំណល់នៅរាជធានីភ្នំពេញ មានការកាត់បន្ថយ ចុះ មិនតែប៉ុណ្ណោះ ជាផ្នែកមួយធ្វើអោយរាជធានីភ្នំពេញមួយនេះ ពោរពេញដោយភាពស្រស់ ស្អាត សោភណភាព និងភាពទាក់ទាញសម្រាប់ភ្ញៀវបរទេសក្នុងសាកលលោកយើងផងដែរ ។

# អនុសាសន៍

ដោយផ្អែកទៅលើសេចក្តីសន្និដ្ឋានដូចបានរៀបរាប់ខាងលើ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីជាយោបល់មួយក្នុងការជួយពង្រឹងនូវការគ្រប់គ្រងកាកសំណល់រឹងនៅរាជធានីភ្នំពេញ ៖

- នៅតាមទីសាធារណៈគួរតែមានភ្នាក់ងារប្រចាំផាកពិន័យ នៅពេលមានការបោះសំរាមពាសវាលពាសកាល ដើម្បីការអនុវត្តវិធានការច្បាប់មានប្រសិទ្ធិភាព
- គួរតែពង្រឹងចលនាបង្រួមគំលាតរវាង អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងក្រុមហ៊ុនប្រមូលសំរាមកែលម្អ និងរក្សានិរន្តរភាព ប្រសិទ្ធិភាពនៃការសំអាតនៅគ្រប់មូលដ្ឋានសង្កាត់ ដោយកំណត់អោយបាននូវបញ្ហាប្រឈមជាក់ស្តែងនៅមូលដ្ឋាន
- គួរតែពង្រឹងចលនានៃការគ្រប់គ្រង និងកាត់បន្ថយក្នុងការប្រើប្រាស់ថង់ប្លាស្ទិក
- គួរតែមានការចុះអប់រំ ប្រជាពលរដ្ឋអំពីការវែកញែក និងទុកដាក់សំរាម ជាប្រចាំ និងដាក់ការតាមដាន ទៅលើអ្វីដែលធ្លាប់ទទួលបានអំពីការរៀន និង ការអនុវត្តន៍ផ្ទាល់របស់ប្រជាពលរដ្ឋ
- សាលារាជធានីភ្នំពេញគួរតែមានវិធានការសំខាន់ផ្សេងៗ ទៅលើកង្វះខាតរបស់ក្រុមហ៊ុនឯកជននៃផែនការសកម្មភាព ដើម្បីអោយក្រុមហ៊ុនឯកជនធ្វើការងារ និងធ្វើសកម្មភាពដោយប្រុងប្រយ័ត្ន និងទំនួលខុសត្រូវខ្ពស់។ ឧទាហរណ៍ ដូចក្នុងករណីភាពយឺតយ៉ាវនៃការប្រមូលសំរាម នៅតាមតំបន់ដែលខ្លួនប្រតិបត្តិ
- សាលារាជធានីគួរតែមានការរៀបចំកម្មវិធីថ្មី និងប្លែកប្រចាំខែ ដោយដាក់អោយថ្នាក់មូលដ្ឋានអនុវត្តន៍ដោយ តាមភូមិនីមួយៗ អាចថាមានការដឹកនាំដោយ មេភូមិ និងរៀបចំការរើសសំរាមប្រចាំសប្តាហ៍ ឬ ប្រចាំខែ ហើយការចំនាយរយះពេលត្រឹមតែ ១ម៉ោង ក្នុងការរើសសំរាម ហើយជាងនេះទៅទៀត អ្នកចូលរួមនោះ គឺប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងភូមិនោះផ្ទាល់តែម្តង។ គោលបំណងនោះ គឺ (ទី១) បង្កើតអោយទម្លាប់អោយចេះស្រលាញ់បរិស្ថាន (ទី២) គឺថា ធ្វើអោយគាត់កាត់បន្ថយការចោលសំរាមរបស់គាត់ បើប្រជាពលរដ្ឋចោលសំរាមច្រើន នោះ ខ្លួនគាត់ផ្ទាល់នឹងត្រូវរើសខ្លួនឯងដដែល ដូច្នេះចង់មិនចង់ គាត់និងកាត់បន្ថយសំរាមបានដោយខ្លួនគាត់ និង (ទី៣) គឺប្រជាពលរដ្ឋនៅក្នុងភូមិ ត្រូវមានទំនាក់ទំនងគ្នាល្អ ដោយការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក អំឡុងពេលធ្វើយុទ្ធនាការណ៍ រើសសំរាម ប្រចាំសប្តាហ៍ ឬប្រចាំខែ របស់ពួកគាត់ ។

# ឯកសារយោង

- កម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានីភ្នំពេញ ២០១៧-២០១៩
- គោលការណ៍ណែនាំបច្ចេកទេស ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- សៀវភៅណែនាំ ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានី ឆ្នាំ២០១០
- របាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ២០១៥ និង ទិសដៅអនុវត្តការងារឆ្នាំ២០១៦ របស់រដ្ឋបាលរាជធានីភ្នំពេញ
- សៀវភៅសិក្ខាសាលាស្តីពី ការកំណត់ភារកិច្ច និងយុទ្ធសាស្ត្រកែលំអការអនុវត្តន៍ ការងារគ្រប់គ្រង និង ការផ្តល់សេវាសំអាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ឆ្នាំ ២០១៣
- សៀវភៅ រាជធានីជ័យលាភីនិរន្តរភាពបរិស្ថានទីក្រុងអាស៊ាន និងវិញ្ញាបនបត្រទទួលស្គាល់ឆ្នាំ ២០១៤
- របាយការណ៍បូកសរុបលទ្ធផលការងារ របស់ក្រុមហ៊ុន ស៊ីនទ្រី ឆ្នាំ ២០១៦
- ផែនការ និងយុទ្ធសាស្ត្រអនុវត្ត ដើម្បីសម្រេចគោលដៅ រាជធានីភ្នំពេញគ្មានសំរាម ឆ្នាំ២០១៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្តោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្តោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្តាលមកពីភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់ភក់ពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្តល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្មនិងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។

គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។

ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្ត៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទីថ្ម និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជីឯកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្ត របស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់ បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុង មាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទី សាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំង សិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កកពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្តឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២( ដប់ពីរ )ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ឧបសម្ព័ន្ធទី១
## សន្ទានុក្រម

១- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់។

២- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព អាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់។

៣- **សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព ផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់។

៤- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារជាតុផ្ទុះ សារជាតុឆេះ សារជាតុចំលងជំងឺ ឬធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជំងឺមហារីក ឬសារជាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

៥- **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជីកំប៉ុស្តិ៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

៦- **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

៧- **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

៨- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើត សម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

៩- **ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថាន សម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

១០- **ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន ដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ). ការដកយក ឬកម្ទេចចោលជាតិពុល សារជាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

១១- **ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

១២- **ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

១៣- **អាងស៊ិបទិក** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

១៤- **ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើសទៅនឹងបញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

១៥- **សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

# ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គីសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាបថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន** **ក្រសួងមហាផ្ទៃ**

លេខៈ ១០៧០.ស.ជ.ណ្ណប.ស្ត

# សារាចរអន្តរក្រសួង

## ស្តីពី

## ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាព សាធារណៈ និងបរិស្ថាន រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ អនុក្រឹត្យនេះមានគោលដៅប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅរដ្ឋបាលខណ្ឌ ដែលជារបត់នៃការគ្រប់គ្រងថ្មីមួយស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

ដើម្បីធានាបាននូវការអនុវត្តអនុក្រឹត្យនេះ ប្រកបដោយភាពរលូន ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក៏ដូចជាសំដៅកាត់បន្ថយបញ្ហាប្រឈមនានាពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលកំពុងកើតមាននៅតាមបណ្តាទីប្រជុំជនរាជធានី ខេត្ត ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានសូមធ្វើការណែនាំការអនុវត្តមួយចំនួនដូចខាងក្រោម ៖

**១. ថ្នាក់ជាតិ៖**

ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំបង្កើតក្រុមការងារអន្តរក្រសួងមួយដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋបាលខេត្ត ទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឲ្យរដ្ឋបាលខណ្ឌ។

ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម៖

- រៀបចំការផ្សព្វផ្សាយអនុក្រឹត្យ និងលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ចុះសិក្សា ប្រមូលព័ត៌មាន និងរៀបចំផែនការដើម្បីសម្របសម្រួលដល់ការផ្ទេរ និងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ពិនិត្យតាមដាន វាយតម្លៃ និងរៀបចំសិក្ខាសាលាដើម្បីឆ្លុះបញ្ចាំង និងដកស្រង់បទពិសោធន៍លើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- រៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនានាអំពីការអនុវត្តអនុក្រឹត្យនេះ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

**២. រដ្ឋបាលរាជធានី ត្រូវៈ**

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលខណ្ឌ សង្កាត់ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីពិនិត្យលទ្ធភាពក្នុងការធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងសង្កាត់នូវមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមួយផ្នែក ឬទាំងស្រុង ដោយភ្ជាប់ជាមួយធនធាន មធ្យោបាយ និងសម្ភារ

- ពិនិត្យការអនុវត្តកិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីធ្វើការកែសម្រួលកិច្ចសន្យា ដោយពិនិត្យលទ្ធភាពក្នុងការផ្ទេរការអនុវត្តកិច្ចសន្យាទៅឱ្យរដ្ឋបាលខណ្ឌឱ្យស្របទៅនឹងតម្រូវការជាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការសហការចូលរួមពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ

- ចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីជានាប្រសិទ្ធភាពក្នុងការប្រមូលនិងដឹកជញ្ជូន

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងបម្រុងទុកសម្រាប់រៀបចំទីលាន ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងរាជធានី និងខេត្តដែលមានព្រំប្រទល់ជាប់គ្នា

- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដូចដូចមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

**៣. រដ្ឋបាលខេត្ត ត្រូវៈ**

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទីភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយត្រូវពិនិត្យ និងបែងចែកធនធានមធ្យោបាយ និងសម្ភារដែលបាននិងកំពុងប្រើប្រាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យ

រដ្ឋបាលក្រុង ស្រុក

- ពិនិត្យការអនុវត្តកិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលបាន និងកំពុងអនុវត្ត និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីកែសម្រួលកិច្ចសន្យា និងផ្ទេរការចុះកិច្ចសន្យា និងការគ្រប់គ្រងការអនុវត្តកិច្ចសន្យាទៅឱ្យរដ្ឋបាលក្រុង ស្រុកឱ្យស្របទៅនឹងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- ណែនាំ សម្របសម្រួល និងជំរុញដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការសហការចូលរួមពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ

- ជំរុញ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុកក្នុងការពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងការសិក្សាស្វែងរកទីតាំងសម្រាប់រៀបចំទីលាន ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងក្រុង ស្រុកដែលមានព្រំប្រទល់ជាប់គ្នា

- តាមដាន ត្រួតពិនិត្យការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដូចមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

### ៤. រដ្ឋបាលខណ្ឌ សង្កាត់ក្នុងរាជធានី៖

- រដ្ឋបាលខណ្ឌត្រូវផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន រដ្ឋបាលសង្កាត់ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឲ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលរាជធានី

- រដ្ឋបាលសង្កាត់ត្រូវបន្តផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងដល់រដ្ឋបាលរបស់ខ្លួន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ ត្រូវអនុវត្តតួនាទី ភារកិច្ចផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលរាជធានី។

### ៥. រដ្ឋបាលក្រុង ស្រុក ត្រូវ៖

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន រដ្ឋបាលឃុំ សង្កាត់ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ពិនិត្យលទ្ធភាពក្នុងការធ្វើប្រតិភូកម្មមុខងារមួយផ្នែកនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់

- សហការពិនិត្យលើការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន

ពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីកែសម្រួលកិច្ចសន្យាឱ្យស្របទៅនឹងតម្រូវការដាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- ក្នុងករណីមិនទាន់មានសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវរៀបចំឱ្យមានសេវាគ្រប់គ្រងនេះ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- សិក្សាឱ្យបានច្បាស់លាស់ពីស្ថានភាពនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានជាអាទិ៍ប្រភេទ ប្រភព និងបរិមាណសំណល់

- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយមន្ទីរ និងអង្គភាពជំនាញ រួមជាមួយការលើកកម្ពស់ការកាត់បន្ថយបរិមាណសំណល់ដែលត្រូវបានបង្កើត និងត្រូវបានបោះបង់ចោល

- ផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយលើកកម្ពស់ការញែកនៅនឹងប្រភព ការវេចខ្ចប់ និងការបញ្ចេញឱ្យបានត្រឹមត្រូវនូវសំរាម សំណល់រឹងទីប្រជុំជន និងការចូលរួមកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន

- ចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងប្រមូល និងដឹកជញ្ជូន

- សហការជាមួយរដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពជំនាញដើម្បីសិក្សាពីស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងសម្រាប់រៀបចំទីលានថ្មីដោយផ្តោតលើទីតាំងដែលមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងក្រុង ស្រុកដែលមានព្រំប្រទល់ជាប់គ្នា ដើម្បីស្នើសុំការពិនិត្យ សម្រេចពីរដ្ឋបាលខេត្ត និងក្រសួងបរិស្ថាន

- អនុវត្តនូវតួនាទី និងភារកិច្ចផ្សេងទៀតដូចដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

### ៦. រដ្ឋបាលឃុំក្នុងស្រុក និងសង្កាត់ក្នុងក្រុង ត្រូវ៖

- បន្តផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដែលមានចែងក្នុងអនុក្រឹត្យ និងមុខងារដែលទទួលបានពីការផ្ទេរប្រតិភូកម្មពីរដ្ឋបាលក្រុង ស្រុក

- អនុវត្តតួនាទី ភារកិច្ចផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣ និងមុខងារដែលទទួលបានពីការផ្ទេរប្រតិភូកម្មពីរដ្ឋបាលក្រុង ស្រុក។

### ៧. មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវ៖

- ផ្សព្វផ្សាយដល់មន្ត្រី បុគ្គលិកក្នុងអង្គភាពរបស់ខ្លួនអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ចូលរួមសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាពដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ

- ចូលរួមពិនិត្យយន្តការ និងកិច្ចសន្យាក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ ដើម្បីឲ្យស្របតាមស្មារតីអនុក្រឹត្យលេខ១១៣

- ចូលរួម និងសហការក្នុងការសិក្សាអំពីស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលកំពុងអនុវត្ត និងអំពីលទ្ធភាពអនុវត្តការញែកសំរាម សំណល់រឹងដែលអាចកែច្នៃ ឬ អាចទាញយកធនធានបាន និងការកាត់បន្ថយការបង្កើតសំណល់

- ចូលរួមសហការរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងសំណើឬ គម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ចូលរួមសហការសិក្សា និងផ្តល់យោបល់លើការស្វែងរកទីតាំងសម្រាប់រៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញការអនុវត្តវិធានការច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- អនុវត្តតួនាទី ភារកិច្ចផ្សេងទៀត ដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣។

ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរបរិស្ថានរាជធានី ខេត្តត្រូវសហការផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាក្រុងភ្នំពេញ

លេខ: ៤៦០ ភក

ភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៧

## ដីកា
## ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ

## អភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល កម្ពុជា ស្តីពីការគ្រប់គ្រងសំណល់រឹង ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៣/០៥៩ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការតែងតាំងអភិបាលរាជធានីភ្នំពេញ ។
- បានឃើញប្រកាសអន្តរក្រសួងមហាផ្ទៃ-ក្រសួងបរិស្ថាន លេខ៨០ ប្រក មផ-បស្ថ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញប្រកាសលេខ ៣៣ ប.ស្ថ ប្រក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរបរិស្ថានខេត្ត ក្រុង ។
- បានឃើញលិខិតលេខ ៣២២ សជណ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីបញ្ហាទីលានចាក់សំរាម ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០០៧ ។
- បានឃើញលក្ខន្តិកៈរបស់អង្គភាពរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៣។
- បានឃើញកិច្ចសន្យា ស្តីពីការសំអាត ប្រមូល និងដឹកជញ្ជូនសំរាមចេញក្រៅរាជធានីភ្នំពេញ រវាងសាលាក្រុងភ្នំពេញ និងក្រុមហ៊ុន ភី អេស ប៊ី ខេ ឌីវើឡុបមែន ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ។
- បានឃើញកិច្ចព្រមព្រៀងបន្ថែម ស្តីពីការបញ្ចេញចោលសំណល់រឹង រវាងសាលាក្រុងភ្នំពេញ និងក្រុមហ៊ុនស៊ិនទ្រី ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០២ ។

## សំរេច



Scanned by CamScanner

ប្រការ ១.    **បទបញ្ញត្តិទូទៅ**

១.១. ដីកានេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម សំណល់រឹងផ្សេងៗក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។

១.២. ដីកានេះមានគោលដៅកំណត់ និងអនុវត្តការគ្រប់គ្រងសំណល់រឹងប្រកបដោយបរិក្ខារបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាអោយបាននូវការការពារ សុខភាពសាធារណៈ គុណភាពបរិស្ថាន និងអភិរក្សជីវៈចំរុះ ។

១.៣ និយមន័យនៃពាក្យបច្ចេកទេសដែលប្រើក្នុងដីកានេះត្រូវបានបកស្រាយដូចតទៅ :

១.៣.១. **សំណល់រឹង :** គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬកំទេចកំទី ដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវអោយបោះបង់ចោល ។

១.៣.២. **សំរាម :** គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយដែលត្រូវបានបញ្ចេញពីលំនៅដ្ឋាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

១.៣.៣. **សំណល់ប្រកបដោយគ្រោះថ្នាក់ :** គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចម្លងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំអោយមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការប៉ះពាល់ធ្ងន់ធ្ងរដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីទីលំនៅដ្ឋាន រោងចក្រ ឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្ម អាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៣៦ អនក្រ បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង។

១.៤. ការបោះចោល ឬចាក់ចោលសំរាម សំណល់រឹងរាយប៉ាយមានជាអាទិ៍ តាមដងផ្លូវ ទីសាធារណៈ ទីប្រជុំជន ទីផ្សារ កន្លែងកំសាន្ត មណ្ឌលទេសចរណ៍ រមណីយដ្ឋាន ឬដូនីយដ្ឋាន ទីវាលស្រែចំការ



Scanned by CamScanner

បឹងបួ តំបន់ការពារ តំបន់ឆ្នេរទន្លេ ច្រាំងទន្លេ ប្រភពទឹកប្រើប្រាស់ ផ្លូវនាវាចរ ប្រព័ន្ធបង្ហូរទឹក លូ ប្រព័ន្ធប្រឡាយកសិកម្មត្រូវហាមឃាត់ជាដាច់ខាត។

១.៥. សំរាម សំណល់រឹងដែលប្រមូល ត្រូវយកទៅចាក់នៅរណ្ដៅ ឬទីលានចាក់សំរាមដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច និងសាលាក្រុងភ្នំពេញ។ ការចាក់ចោលសំរាម សំណល់រឹងនៅ ក្នុងបរិវេណ ឬដីកម្មសិទ្ធិឯកជនក្នុងគោលបំណងណាក៏ដោយត្រូវបានហាមឃាត់ជាដាច់ខាត។

១.៦. ការដុតសំរាម សំណល់រឹងគ្រប់ប្រភេទ ទោះស្ថិតក្នុងទីលាន ឬរណ្ដៅចាក់សំរាមក្ដី ត្រូវហាមឃាត់ជាដាច់ខាត។

១.៧. ហាមឃាត់ជាដាច់ខាតចំពោះការប្រមូល ការដឹកជញ្ជូន និងការបោះចោលសំរាម សំណល់រឹង ដែលលាយបញ្ចូលជាមួយសំណល់រឹងពុល ឬប្រកបដោយគ្រោះថ្នាក់។

## ប្រការ ២. ភារកិច្ចរបស់ក្រុមហ៊ុនស៊ីនទ្រី

ក្រុមហ៊ុនស៊ីនទ្រីត្រូវទទួលខុសត្រូវ និងបំពេញនូវភារកិច្ចមានអាទិ ដូចតទៅ:

២.១. ត្រូវរៀបចំផែនការសកម្មភាពស្ដីពីកម្មវិធីនៃការប្រមូលសំរាម សំណល់រឹងនៅក្នុងតំបន់ផ្ដល់សេវាកម្មរបស់ខ្លួន ហើយត្រូវបញ្ជូនមកសាលាក្រុងភ្នំពេញ និងត្រូវចម្លងជូនមន្ទីរបរិស្ថានដើម្បីធ្វើការពិនិត្យឯកភាព និងធ្វើការតាមដានអនុវត្ត។

២.២. ត្រូវសំអាត បោស កៀរដី និងប្រមូលសំរាមជាអាទិ តាមមហាវិថី វិថី ផ្លូវលំ ច្រកផ្លូវ ផ្លូវថ្នល់មាត់ប្រឡាយ ចិញ្ចើមផ្លូវជាប់គ្រឹះស្ថានសាធារណៈ គ្រឹះស្ថានឯកជន និងប្រមូលសំរាមតាមលំនៅដ្ឋានសាធារណៈជនទាំងអស់ក្នុងរាជធានីភ្នំពេញ ហើយត្រូវដឹកជញ្ជូនយកទៅចាក់ចោលនៅទីលានចាក់សំរាមអោយបានទៀងទាត់តាមពេលវេលាដែលបានកំណត់ក្នុងកម្មវិធី លើកលែងតែតំបន់សេសសល់ដែលគ្រប់គ្រងដោយអង្គភាពរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ។

២.៣. ត្រូវរៀបចំដាក់ធុងសំរាមសាធារណៈឱ្យបានគ្រប់គ្រាន់ មានជាអាទិ នៅតាមសួនច្បារសាធារណៈ ទីកន្លែងកំសាន្តនានា នៅត្រង់ចំនុចណាមួយក្បែរគ្រឹះស្ថានសាធារណៈ គ្រឹះស្ថានឯកជន ភោជនីយដ្ឋាន ក្លឹបកំសាន្ត គេហដ្ឋានរបស់ប្រជាពលរដ្ឋ តាមការកំណត់របស់ អាជ្ញាធរខណ្ឌ សង្កាត់ ទៅតាមស្ថានភាពជាក់ស្ដែង ដើម្បីបង្ករភាពងាយស្រួលក្នុងការស្ដុកជាបណ្ដោះអាសន្ន នូវសំរាម សំណល់



Scanned by CamScanner

រឹង ជៀសវាងការដាក់ចោលសំរាមរាយប៉ាយតាមដងផ្លូវសាធារណៈ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការធ្វើចរាចរ សោភ័ណភាព អនាម័យ និងបរិស្ថាននៅក្នុងរាជធានីភ្នំពេញ ។

២.៤. ត្រូវដឹកសំរាមពីសួនសាធារណៈដែលបានសំអាតរួច ជាពិសេសក្នុងពេលមានទិវាបុណ្យជាតិ និងអន្តរជាតិនានាដោយត្រូវបង្កើនសេវាកម្មដើម្បីធានាបរិស្ថានស្អាត និងអនាម័យល្អ ។

២.៥. ត្រូវប្រមូលសំរាមពីទីផ្សារឱ្យបានស្អាត រួចយកទៅចាក់ចោលនៅទីលានចាក់សំរាមឱ្យបានទៀងទាត់ និងទាន់ពេលវេលាស្របទៅតាមកម្មវិធីដែលបានកំនត់ លើកលែងការប្រមូលសំរាមនៅផ្សារដើមគរ ។

២.៦. នៅពេលដឹកសំរាមទៅកាន់ទីលានចាក់សំរាម មិនត្រូវបណ្តោយឱ្យហូរទឹកស្អុយ និងជ្រុះសំរាមរាយប៉ាយតាមដងផ្លូវឡើយ ។

២.៧. ត្រូវធានាសំអាត ប្រមូលសំរាម និងដឹកជញ្ជូនចេញឱ្យបានទាន់ពេលវេលាតាមតំបន់ និងទីតាំងសំខាន់ៗក្នុងរាជធានីភ្នំពេញដែលមាន ថ្នាក់ដឹកនាំជាន់ខ្ពស់ ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិឆ្លងកាត់ និងធ្វើដំណើរទស្សនកិច្ច តាមសេចក្តីជូនដំណឹងរបស់សាលាក្រុងភ្នំពេញ ។

២.៨. ត្រូវធ្វើរបាយការណ៍ជាប្រចាំរៀងរាល់ខែជូនសាលាក្រុងភ្នំពេញ និងចម្លងជូនមន្ទីរបរិស្ថាន ព្រមទាំងអង្គភាពដែលពាក់ព័ន្ធ ស្តីពីលទ្ធផលការងារ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហើយត្រូវធ្វើការចូលរួមប្រជុំឱ្យបានទៀងទាត់តាមការអញ្ជើញរបស់សាលាក្រុងភ្នំពេញ ។

២.៩. យានយន្តដឹកសំរាម ត្រូវបំពាក់ឧបករណ៍ដែលមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ ក្នុងការផ្តល់សេវាកម្មប្រមូល និងដឹកជញ្ជូនសំរាម ។

២.១០. ត្រូវបង្កើនគុណភាពសេវាកម្មក្នុងការប្រមូល និងដឹកជញ្ជូនសំរាមចេញក្រៅរាជធានីភ្នំពេញ តាមរយៈការបង្កើនគុណភាព បរិមាណយានយន្តដឹកសំរាមឱ្យបានគ្រប់គ្រាន់ ព្រមទាំងធានាឱ្យមានលក្ខណៈបច្ចេកទេសសមស្របតាមច្បាប់ចរាចរ និងបទដ្ឋាននានាដែលពាក់ព័ន្ធ ។

២.១១. ត្រូវគោរពអនុវត្តតាមតារាងតំលៃដែលកំនត់ដោយសាលាក្រុងភ្នំពេញ លើការប្រមូលថ្លៃសេវាដឹកជញ្ជូនសំរាម ។

២.១២. ត្រូវបង់ថ្លៃសេវាទីលានចាក់សំរាមជូនសាលាក្រុងភ្នំពេញដោយគោរព និងអនុវត្តតាមខ្លឹមសារណែនាំដែលមានចែងនៅក្នុងលិខិតលេខ ៣២២ សជណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៣ ខែមិនា ឆ្នាំ ២០០៧ ឱ្យបានជាកំហិត ។



Scanned by CamScanner

២.១៣. ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការរៀបចំកម្មវិធីអប់រំដល់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ ស្តីពីការសំអាត និងការទុកដាក់សំរាម សំណល់រឹង ឱ្យមានលក្ខណៈត្រឹមត្រូវប្រកបដោយអនាម័យ ។

## ប្រការ ៣. ភារកិច្ចរបស់អង្គភាពរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ

អង្គភាពរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញត្រូវទទួលខុសត្រូវ និងមានភារកិច្ចជាអាទិ ដូចតទៅ:

៣.១. ត្រូវគ្រប់គ្រងការប្រមូល សំអាត និងដឹកជញ្ជូនសំណល់រឹង សំរាម នៅតាមទីធ្លាសាធារណៈ ផ្លូវថ្នល់ ចិញ្ចើមថ្នល់ ចិញ្ចើមប្រឡាយ ច្រាំងទន្លេ គេហដ្ឋាន គ្រឹះស្ថាន អាគារសាធារណៈ ទីតាំងអាជីវកម្ម ឧស្សាហកម្ម សិប្បកម្ម ផលិតកម្ម សេវាកម្មនានាក្នុងរាជធានីភ្នំពេញ យកទៅដាក់នៅទីលានចាក់សំរាមសុវត្ថិភាព ។

៣.២. នៅពេលដឹកសំរាមទៅកាន់ទីលានចាក់សំរាម មិនត្រូវបណ្តោយអោយហូរទឹកស្អុយ និងជ្រុះសំរាមរាយប៉ាយតាមដងផ្លូវឡើយ ។

៣.៣. ត្រូវធានា និងបំពេញឱ្យបាននូវការសំអាត និងប្រមូលសំរាមឱ្យបានទាន់ពេលវេលា តាមតំបន និងទីតាំងសំខាន់ៗក្នុងតំបន់គ្រប់គ្រងរបស់ខ្លួន ជាពិសេសក្នុងឱកាសបុណ្យជាតិ និងអន្តរជាតិ ឬនៅពេលមានថ្នាក់ដឹកនាំជាតិជាន់ខ្ពស់ ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិឆ្លងកាត់ និងធ្វើដំណើរទស្សនកិច្ច ។

៣.៤. ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផល និងការលំបាកនានាទាក់ទងនឹងកិច្ចការសំអាត ការប្រមូលសំរាមរួមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុជារៀងរាល់ខែជូនសាលាក្រុងភ្នំពេញ និងចំលងជូនមន្ទីរបរិស្ថាន ។

៣.៥. ត្រូវប្រជុំដោះស្រាយបញ្ហាការលំបាកនានាដែលទាក់ទងនឹងការសំអាត និងការប្រមូលសំរាមក្នុងរាជធានីភ្នំពេញ ។

៣.៦. ត្រូវបង្កើនគុណភាពសេវាកម្មក្នុងការប្រមូល និងដឹកជញ្ជូនសំរាមចេញក្រៅរាជធានីភ្នំពេញ តាមរយៈការបង្កើនគុណភាព បរិមាណយានយន្តដឹកសំរាមនានាឱ្យបានគ្រប់គ្រាន់ ព្រមទាំងធានាឱ្យមានលក្ខណៈបច្ចេកទេសសមស្របតាមច្បាប់ចរាចរ និងបទដ្ឋាននានាដែលពាក់ព័ន្ធ ។

៣.៧. ត្រូវសហការជាមួយអង្គភាពជំនាញ និងអាជ្ញាធរមូលដ្ឋានដើម្បីរៀបចំកម្មវិធីអប់រំដល់ប្រជាពលរដ្ឋក្នុងការសំអាត និងទុកដាក់សំរាមឱ្យមានអនាម័យល្អ ។



Scanned by CamScanner

៣.៨. ត្រូវត្រួតពិនិត្យឱ្យបានជាប់ជាប្រចាំ ដោយផ្ដោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រង និងថែទាំទីលានចាក់សំរាមឱ្យមានលក្ខណៈប្រកបដោយអនាម័យល្អ ដើម្បីកាត់បន្ថយការប៉ះពាល់ដែលអាចឱ្យមានគ្រោះអប្បបរមា ។

៣.៩. ករណីដែលទីលានចាក់សំរាមមានសភាពពេញហៀរ អង្គភាពរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញត្រូវរៀបចំកម្មវិធីកែច្នៃការប្រើប្រាស់រណ្ដៅ ឬទីលានចាក់សំរាមឡើងវិញដោយមិនបង្កឱ្យមានការរាំងស្ទះដល់ការចាក់សំរាម សំណល់រឹងដែលកំពុងដំណើរការឡើយ ។

៣.១០. ត្រូវសហការជាមួយអង្គការ JICA ក្នុងការរៀបចំទីលានចាក់សំរាមថ្មី ដោយត្រូវផ្ដោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការកាត់បន្ថយការបំពុលបរិស្ថាន និងការប៉ះពាល់សុខភាពសាធារណៈដោយអនុលោមតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងសាលាក្រុងភ្នំពេញ ។

## ប្រការ ៤. ភារកិច្ចរបស់មន្ទីរបរិស្ថានរាជធានីភ្នំពេញ

មន្ទីរបរិស្ថានរាជធានីភ្នំពេញត្រូវទទួលខុសត្រូវ និងមានភារកិច្ចជាអាទិ ដូចតទៅ:

៤.១. ត្រូវធ្វើជាសេនាធិការឱ្យសាលាក្រុងភ្នំពេញក្នុងការរៀបចំផែនការគ្រប់គ្រង និងចូលរួមធ្វើផែនការសកម្មភាពក្នុងការប្រមូល ការស្តុកទុកបណ្ដោះអាសន្ន ការដឹកជញ្ជូន និងការចាក់ចោលសំរាម សំណល់រឹងក្នុងដែនដីរាជធានីភ្នំពេញ ។

៤.២. ត្រូវចូលរួមសហការ និងត្រួតពិនិត្យកិច្ចអនុវត្តន៍ការងារដែលមានចែងខាងលើ និងរាយការណ៍រៀងរាល់ខែជូនសាលាក្រុងភ្នំពេញដើម្បីមានវិធានការកែតំរូវ និងអនុវត្តបន្ត ។

៤.៣. ត្រូវត្រួតពិនិត្យផែនការមេ និងលំអិត ស្តីពីកម្មវិធីនៃការប្រមូលសំរាម សំណល់រឹងដែលធ្វើឡើងដោយក្រុមហ៊ុនស៊ិនទ្រី និងអង្គភាពរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ ហើយបញ្ជូនទៅសាលាក្រុងភ្នំពេញដើម្បីពិនិត្យ សំរេច និងធ្វើការតាមដាន ។

៤.៤. ត្រូវលើកផែនការ និងរាយការណ៍ជូនសាលាក្រុងភ្នំពេញ និងជំរាបដល់ក្រុមហ៊ុនស៊ិនទ្រីនូវតំបន់ដែលទើបអភិវឌ្ឍន៍ថ្មី ដើម្បីចាត់ចែងបញ្ចូលក្នុងផែនការមេ និងកម្មវិធីប្រមូលសំរាម ។

៤.៥. ត្រូវសហការជាមួយអាជ្ញាធរខណ្ឌ សង្កាត់ ក្នុងការកំណត់ និងត្រួតពិនិត្យលើការប្រមូល ការស្តុកបណ្ដោះអាសន្ន ការដឹកជញ្ជូន និងការចាក់ចោលសំរាម សំណល់រឹង ដោយត្រូវរៀបចំសេចក្ដីណែ

Scanned by CamScanner

នាំពីការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទាំងនោះ សំរាប់ការស្តុកបណ្តោះអាសន្នមុននឹងធ្វើការប្រមូល និងការដឹកជញ្ជូនយកទៅចាក់ចោលនៅទីលានចាក់សំរាម ។

៤.៦. ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីធ្វើការត្រួតពិនិត្យ ណែនាំ ព្រមាន និងផាកពិន័យចំពោះជនទាំងឡាយណាដែលល្មើសនឹងបទបញ្ញត្តិនៃដីកានេះ ដោយអនុលោមតាមប្រកាសអន្តរក្រសួងមហាផ្ទៃ-ក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ។

៤.៧ ត្រូវអនុវត្តភារកិច្ចបន្ថែមទាក់ទងទៅនឹងការងារបរិស្ថាននៅក្នុងរាជធានីភ្នំពេញ ដោយអនុលោមតាមប្រកាសរបស់ក្រសួងបរិស្ថានលេខ ៣៣ ប.ស្ត ប្រក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មន្ទីរបរិស្ថានខេត្ត ក្រុង ។

## ប្រការ ៥. ភារកិច្ចរបស់អាជ្ញាធរខណ្ឌ សង្កាត់នៅក្នុងរាជធានីភ្នំពេញ

អាជ្ញាធរខណ្ឌ សង្កាត់ក្នុងរាជធានីភ្នំពេញត្រូវទទួលខុសត្រូវ និងមានភារកិច្ចជាអាទិ ដូចតទៅ:

៥.១. ត្រូវសហការជាមួយស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធដើម្បីធ្វើការអប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីការយកចិត្តទុកដាក់ក្នុងការវេចខ្ចប់ ការទុកដាក់ និងការបោះចោលសំរាម សំណល់រឹងទៅតាមទីកន្លែង និងពេលវេលាដែលបានកំណត់ប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន ។

៥.២. ត្រូវជំរុញ និងលើកទឹកចិត្តដល់សកម្មភាពទាញយកមកប្រើប្រាស់ឡើងវិញ ឬកែច្នៃនូវសំរាម សំណល់រឹង នៅក្នុងមូលដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ។

៥.៣. ត្រូវដឹកនាំកំលាំងនគរបាលខណ្ឌ សង្កាត់ និងសហការជាមួយមន្ត្រីបរិស្ថានក្នុងការទប់ស្កាត់ និងផាកពិន័យចំពោះជនទាំងឡាយណាដែលបានបោះចោលសំរាម សំណល់រឹងតាមទីសាធារណៈ ដងផ្លូវ លូ ប្រឡាយ បឹង ទន្លេ ។ល ។

៥.៤. ត្រូវរៀបចំដាក់ផ្លាកសញ្ញាហាមឃាត់ក្នុងការទុកដាក់ និងបោះចោលសំរាម សំណល់រឹងតាមទីកន្លែងសំខាន់ៗ ។

៥.៥. ក្នុងករណីចាំបាច់ ត្រូវកំណត់ និងរៀបចំទីតាំងទុកសំរាម សំណល់រឹងបណ្តោះអាសន្នរួមទាំងធុងសំរាមសាធារណៈឱ្យបានសមស្រប ដោយមិនបង្កបញ្ហានាំអោយប៉ះពាល់ដល់ការធ្វើចរាចរ សុខមាលភាពសាធារណៈ សោភ័ណភាពរាជធានីភ្នំពេញ និងសណ្តាប់ធ្នាប់សង្គម ។



Scanned by CamScanner

៥.៦. ត្រូវធ្វើការតាមដានលើការប្រមូល ការសំអាត ការស្តុក និងការដឹកជញ្ជូនសំរាម សំណល់រឹងទាំងនោះយកទៅចាក់ចោលឱ្យបានទៀងទាត់ជាប្រចាំ នៅទីតាំងចាក់សំរាមដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ឬសាលាក្រុងភ្នំពេញ ។

## ✓ ប្រការ ៦. ភារកិច្ចរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ

ប្រជាពលរដ្ឋគ្រប់រូបក្នុងរាជធានីភ្នំពេញមានភារកិច្ចជាអាទិ ដូចតទៅ:

៦.១. ត្រូវចូលរួមយ៉ាងសកម្មក្នុងការសំអាត ថែទាំអនាម័យទីសាធារណៈ លំនៅដ្ឋាន ជុំវិញលំនៅដ្ឋាន ទីតាំងអាជីវកម្ម សេវាកម្មគ្រប់ប្រភេទ ព្រមទាំងត្រូវការពារ ថែទាំ ធុងសំរាមផ្ទាល់ខ្លួន និងធុងសំរាមសាធារណៈបន្ថែមទៀត ក្នុងគោលបំណងការពារគុណភាពបរិស្ថាន សោភ័ណភាព ទីក្រុង និងសុខមាលភាពសង្គម ។

៦.២. ត្រូវបង់ថ្លៃសេវាប្រមូលសំរាមឱ្យបានទៀងទាត់ ដូចមានចែងក្នុងតារាងតំលៃដែលកំណត់ដោយសាលាក្រុងភ្នំពេញ ។

៦.៣. មិនត្រូវបោះចោលសំរាមតាមដងផ្លូវ តាមទីសាធារណៈក្នុងរាជធានីភ្នំពេញឡើយ ។

៦.៤. ត្រូវញែក និងវេចខ្ចប់សំរាមរបស់ខ្លួនអោយបានត្រឹមត្រូវ ហើយយកទៅដាក់នៅមុខផ្ទះ ឬទីកន្លែងតាមកម្មវិធីដែលបានកំនត់ ។

៦.៥. មិនត្រូវទុកដាក់សំរាមឱ្យរាយប៉ាយ ឬហូរទឹកស្អុយកខ្វក់នៅមុខផ្ទះ ដីឡូតិ៍ ឬជុំវិញភូមិដ្ឋានរបស់ខ្លួនឡើយ ។

## ✓ ប្រការ ៧. ទោសប្បញ្ញត្តិ

ជនទាំងឡាយណាដែលបានអនុវត្តផ្ទុយ និងរំលោភទៅនឹងខ្លឹមសារនៃប្រការដែលបានចែងក្នុង ដីកានេះ នឹងត្រូវទទួលការណែនាំ ការព្រមាន ការផាកពិន័យ និងការផ្តន្ទាទោសអនុលោមតាម ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ និងតាមប្រកាសអន្តរក្រសួងមហាផ្ទៃ-ក្រសួងបរិស្ថាន លេខ៨០ ប្រក មផ-បស្ថ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ។



Scanned by CamScanner

ប្រការ ៨. អនុសាសន៍បញ្ញត្តិ

អភិបាលរងរាជធានីភ្នំពេញ នាយខុទ្ទកាល័យសាលាក្រុងភ្នំពេញ ប្រធានមន្ទីរបរិស្ថានរាជធានីភ្នំពេញ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាលខណ្ឌទាំង ៧ និងចៅសង្កាត់ទាំងអស់ក្នុងរាជធានីភ្នំពេញ អភិបាលរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ នាយកក្រុមហ៊ុនស៊ីនទ្រី ព្រមទាំងប្រជាពលរដ្ឋគ្រប់រូបក្នុងរាជធានីភ្នំពេញ ត្រូវអនុវត្តដីកានេះអោយមានប្រសិទ្ធិភាពទៅតាមសមត្ថកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អភិបាលរាជធានីភ្នំពេញ

គែប ជុតិមា

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងផែនការ
- ក្រសួងសាធារណការ និងដឹកជញ្ជូន

(ដើម្បីជូនជ្រាប)

- មន្ទីរបរិស្ថានរាជធានីភ្នំពេញ
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ
- មន្ទីរផែនការរាជធានីភ្នំពេញ
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- សាលាខណ្ឌទាំង ៧
- រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ
- អគ្គនាយកក្រុមហ៊ុនស៊ីនទ្រី

(ដើម្បីសហការអនុវត្ត)

- ឯកសារ- កាលប្បវត្តិ



Scanned by CamScanner